# ធនាគារ ហត្ថា ម.ក
# និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

(ចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០៥៣៥៥)

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល និង របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកដែលបានធ្វើសវនកម្ម

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

**ធនាគារ ហាណា ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធ**

**របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## មាតិកា


| | ទំព័រ |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ - ៥ |
| របាយការណ៍របស់សវនករឯករាជ្យ | ៦ - ១១ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម | ១២ |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម | ១៣ |
| របាយការណ៍បម្រែបម្រួលមូលធនរួម | ១៤ |
| របាយការណ៍លំហូរសាច់ប្រាក់រួម | ១៥ - ១៦ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដាច់ដោយឡែក | ១៧ |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដាច់ដោយឡែក | ១៨ |
| របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក | ១៩ |
| របាយការណ៍លំហូរសាច់ប្រាក់ដាច់ដោយឡែក | ២០- ២១ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ២២- ១៩៤ |

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានក្តីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនិងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារហត្ថា ម.ក (ហៅកាត់ថា "ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធហត្ថាស៊ីរីស ឯ.ក (ជារួមហៅកាត់ថា "សម្ព័ន្ធធនាគារ") និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារ (ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ") សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

## សកម្មភាពចម្បង

ធនាគារបានចូលរួមជាចម្បងលើគ្រប់ទិដ្ឋភាពនៃអាជីវកម្មធនាគារ និងការផ្តល់សេវាពាក់ព័ន្ធហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺការទិញ ការលក់ ការជួល និងការធ្វើអាជីវកម្មអចលនវត្ថុផ្ទាល់ខ្លួន ឬជួលពីគេ។

ក្នុងអំឡុងឆ្នាំនេះ ពុំមានការផ្លាស់ប្តូរជាសារវន្តចំពោះសកម្មភាពសំខាន់ៗទាំងនេះទេ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| សម្ព័ន្ធធនាគារ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| (ខាត)/ប្រាក់ចំណេញមុនដកពន្ធ | (៥៣.៩៩៨.៩១៦) | (២២១.៩៣៥.៥៤៦) | ៩២.១៧២.៨៩១ | ៣៧៦.៧១០.៦០៤ |
| អត្ថប្រយោជន៍/(ចំណាយ)ពន្ធលើប្រាក់ចំណេញ | ១០.៤៤៦.២៦៥ | ៤២.៩៣៤.១៥០ | (១៨.៣២៩.២៤០) | (៧៤.៩១១.៦០៤) |
| (ខាត)/ប្រាក់ចំណេញក្នុងគ្រា | (៤៣.៥៥២.៦៥១) | (១៧៩.០០១.៣៩៦) | ៧៣.៨៤៣.៦៥១ | ៣០១.៧៩៩.០០០ |

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| ធនាគារ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| (ខាត)/ប្រាក់ចំណេញមុនដកពន្ធ | (៥២.៧៣៩.៩៤៤) | (២១៦.៧៦១.១៧១) | ៩២.៣៣៧.០៦៦ | ៣៧៧.៣៨១.៥៨៧ |
| អត្ថប្រយោជន៍/(ចំណាយ)ពន្ធលើប្រាក់ចំណេញ | ១០.១៩៨.២៧៣ | ៤១.៩១៤.៩០២ | (១៨.៤៦៧.៩១៣) | (៧៥.៤៧៨.៣៦០) |
| (ខាត)/ប្រាក់ចំណេញក្នុងគ្រា | (៤២.៥៤១.៦៧១) | (១៧៤.៨៤៦.២៦៩) | ៧៣.៨៦៩.១៥៣ | ៣០១.៩០៣.២២៧ |

## ភាគលាភ

ពុំមានភាគលាភត្រូវបានប្រកាស ឬបែងចែកក្នុងអំឡុងការិយបរិច្ឆេទនេះទេ (២០២២៖ ពុំមាន)។



ធនាគារ ហត្ថា ម.ក - ការិយាល័យកណ្តាល | HATTHA BANK PLC. - HEAD OFFICE
អគារលេខ៦០៦ ផ្លូវ២៧១ សង្កាត់បឹងទំពន់១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ប្រអប់សំបុត្រ៖២០៤៤
No. 606, Street. 271, Sangkat Boeng Tumpun 1, Khan Mean Chey, Phnom Penh, Cambodia. P.O. Box: 2044
023 999 266 | 1800 212 222 (Toll Free) info@hatthabank.com www.hatthabank.com

## ដើមទុន

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជា បានអនុម័តសំណើររបស់ធនាគារក្នុងការបង្កើនដើមទុនចំនួន២៥លានដុល្លារអាមេរិក ពី១១៥លានដុល្លារអាមេរិក ដល់ ១៤០លានដុល្លារអាមេរិក។ ការកែតម្រូវលក្ខន្តិកៈរបស់ធនាគារ ត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២១។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធន នៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការលុបចេញពីបញ្ជី និងសំវិធានធនលើទ្រព្យសកម្មហិរញ្ញវត្ថុ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមាន មូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាសកម្មភាពត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងការលុបចេញពីបញ្ជីលើទ្រព្យសកម្មហិរញ្ញវត្ថុដែល មិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវលំហូរសាច់ប្រាក់តាមកិច្ចសន្យាទាំងស្រុង ឬចំណែកណាមួយ និងបានធ្វើសំវិធានធនលើការខាតបង់ពីឱនភាពតម្លៃទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានដឹងថានឹងមិនមានការរំពឹងទុកថា អាចប្រមូលបានមកវិញនូវលំហូរសាច់ប្រាក់តាមកិច្ចសន្យា ត្រូវបានលុបចោល និងបានធ្វើសំវិធានធនគ្រប់គ្រាន់ ចំពោះការខាតបង់ពីឱនភាពតម្លៃទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលការលុបចេញពីបញ្ជី ឬ សំវិធានធនលើការខាតបង់ពីឱនភាពតម្លៃទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនោះទេមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងអស់ (លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុ) ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់សម្ព័ន្ធធនាគារ និងធនាគារដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារថាមានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យមានផលប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលកើតមានឡើង ចាប់តាំងពីចុងការិយបរិច្ឆេទបញ្ចប់ ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ក្រៅអំពីការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

(ខ) បំណុលយថាហេតុណាមួយ ដែលកើតមានឡើងចំពោះសម្ព័ន្ធធនាគារ និងធនាគារ ចាប់តាំងពីចុងការិយបរិច្ឆេទបញ្ចប់ ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារ។

ក្រុមប្រឹក្សាភិបាលមានមតិយោបល់ថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវសង ឬអាចនឹងត្រូវសងក្នុងរយៈពេល១២ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឱ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដល់កាលកំណត់សង។

## បម្រែបម្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលនឹងអាចបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលមានមតិថានៅក្នុងចន្លោះពេលចាប់ពីការិយបរិច្ឆេទបញ្ចប់រហូតដល់ កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍បន្ទាប់ពីដំណាច់ការិយបរិច្ឆេទ

តាមការយល់ដឹងរបស់ក្រុមប្រឹក្សាភិបាលនៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍ជាសារវន្តដែលកើតឡើងបន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍ដែលតម្រូវឱ្យមានការកែតម្រូវឬបង្ហាញក្រៅពីអ្វីដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទនិងគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន៖

- លោក Dan Harsono ជាប្រធានក្រុមប្រឹក្សាភិបាលនិង ជាអ្នកប្រឹក្សាជាន់ខ្ពស់របស់ Krungsri (ចូលនិវត្តន៍នៅថ្ងៃទី ១ ខែមករា ឆ្នាំ២០២៣)
- លោក Phonganant Thanattrai ជាប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានផ្នែកRetail and Consumer Banking របស់ Krungsri (តែងតាំងនៅថ្ងៃទី ១ ខែមករា ឆ្នាំ២០២៣)
- លោក Chandrashekar Subramanian Krishoolndmangalam ជាអភិបាល និងអគ្គនាយកផ្នែកគ្រប់គ្រងហានិភ័យ
- លោក Pairote Cheunkrut ជាអភិបាល និងជាអគ្គនាយកផ្នែកយុទ្ធសាស្ត្ររបស់ Krungsri
- អ្នកស្រី Duangdao Wongpanitkrit ជាអភិបាល និងជាអគ្គនាយកផ្នែកហិរញ្ញវត្ថុរបស់ Krungsri
- លោក ហួត អៀងគុង ជាអភិបាល និងជាប្រធានអគ្គនាយករបស់ធនាគារ ហត្ថា ម.ក
- លោក Wanchairabin Jitwattanatam ជាអភិបាល និងជា Executive Vice President របស់ Krungsi
- លោក ឌី ដាវុឌ្ឍ ជាអភិបាលឯករាជ្យ និងជាសកលវិទ្យាធិការរងសកលវិទ្យាល័យបៀលប្រាយ
- លោក ឡុញ ហៃ ជាអភិបាលឯករាជ្យ (ចូលនិវត្តន៍នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២៣)
- លោក ប៉ាក់ សេរីវឌ្ឍនា ជាអភិបាលឯករាជ្យ

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានសម្ព័ន្ធធនាគារ និងធនាគារជាគូភាគី ក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់សម្ព័ន្ធធនាគារ និងធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុននោះទេ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុននេះ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់របស់សម្ព័ន្ធធនាគារ និងធនាគារទទួលបានឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយសម្ព័ន្ធធនាគារ និងធនាគារ ឬធនាគារដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយធនាគារដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែមានការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការធានា របាយការណ៍ហិរញ្ញវត្ថុនូវភាពត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុ របស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ចុងការិយបរិច្ឆេទបញ្ចប់។នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តន៍ប្រកបដោយសង្គតិភាព។
- អនុវត្តទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRSs") ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះ ត្រូវបានបង្ហាញពន្យល់ និង កំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មតថា សម្ព័ន្ធធនាគារ និងធនាគារ នឹងមិនបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគតនិង
- ត្រួតពិនិត្យ និងដឹកនាំសម្ព័ន្ធធនាគារ និងធនាគារ ឱ្យមានប្រសិទ្ធភាព និងចូលរួមរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយណា ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា សម្ព័ន្ធធនាគារ និងធនាគារ បានអនុវត្តនូវរាល់ការតម្រូវដូចបាន រាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែក

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកអមនឹងកំណត់សម្គាល់ដូចដែលបានភ្ជាប់ជាមួយ បានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាម CIFRSs និងត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល ហើយគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា សម្ព័ន្ធធនាគារ និងធនាគារមានលទ្ធភាពក្នុងការទូទាត់បំណុលនៅពេលដល់កំណត់សង។

*ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖*

ធនាគារ ហត្ថា ម.ក
ការិយាល័យកណ្តាល
Head Office
HATTHA BANK PLC.

លោក ហួត អៀងតុង
*ប្រធានអគ្គនាយក*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៤

Deloitte.

Deloitte (Cambodia) Co., Ltd.
Vattanac Capital Tower
Floor 8, Unit 8, #66
Preah Monivong Blvd
Sangkat Voat Phnum
Khan Doun Penh
Phnom Penh, Cambodia.

Tel: +855 23 963 777
Fax: +855 23 963 778
www.deloitte.com/kh

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគទុនិក ធនាគារ ហត្ថា ម.ក

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ ហត្ថា ម.ក (ហៅកាត់ថា "ធនាគារ") និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ ហត្ថា ស៊ីវីស ឯ.ក (ជារួមហៅកាត់ថា "សម្ព័ន្ធធនាគារ") និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក របស់ធនាគារ (ជារួមហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ") ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដាច់ ដោយឡែកនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម និងដាច់ដោយ ឡែក របាយការណ៍ស្តីពីបម្រែបម្រួលមូលធនរួម និងដាច់ដោយឡែក និងរបាយការណ៍លំហូរសាច់ប្រាក់រួម និងដាច់ ដោយឡែកសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ដែលរួមមានព័ត៌មាន គោលនយោបាយគណនេយ្យសារវន្តដែលបានបង្ហាញនៅទំព័រទី១២ ដល់ទី១៩៤។

ជាយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់ជាមួយបង្ហាញនូវភាពត្រឹមត្រូវជាសារវន្តនៃ ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRSs")។

## មូលដ្ឋានសម្រាប់មតិយោបល់សវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CISAs")។ ការទទួលខុសត្រូវរបស់យើងខ្ញុំដោយអនុលោមស្របតាមស្តង់ដាទាំងនេះ ត្រូវបានរៀបរាប់បន្ថែមនៅក្នុងកថាខណ្ឌ ស្តីពី *ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំឯករាជ្យពីសម្ព័ន្ធធនាគារ និងធនាគារដោយស្របទៅតាម *ក្រមសីលធម៌វិជ្ជាជីវៈអន្តរជាតិសម្រាប់គណនេយ្យករ ជំនាញរបស់ក្រុមប្រឹក្សាស្តង់ដាក្រមសីលធម៌វិជ្ជាជីវៈអន្តរជាតិសម្រាប់គណនេយ្យករ (រួមបញ្ចូលស្តង់ដាឯករាជ្យភាព អន្តរជាតិ)* (ហៅកាត់ថា "IESBA Code") រួមទាំងការតម្រូវក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើ របាយការណ៍ហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌ វិជ្ជាជីវៈស្របតាមការតម្រូវរបស់ស្តង់ដាទាំងនោះ និងIESBA Code ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែល យើងខ្ញុំបានទទួល គឺមានភាពគ្រប់គ្រាន់ និងសមរម្យដើម្បីជាមូលដ្ឋានសម្រាប់ការផ្តល់មតិយោបល់របស់យើងខ្ញុំ។



Deloitte refers to one or more of Deloitte Touche Tohmatsu Limited ("DTTL"), its global network of member firms, and their related entities (collectively, the "Deloitte organisation"). DTTL (also referred to as "Deloitte Global") and each of its member firms and related entities are legally separate and independent entities, which cannot obligate or bind each other in respect of third parties. DTTL and each DTTL member firm and related entity is liable only for its own acts and omissions, and not those of each other. DTTL does not provide services to clients. Please see www.deloitte.com/about to learn more

Deloitte.

## បញ្ហាសវនកម្មសំខាន់ៗ

តាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំបញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយណាដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំនេះ។ បញ្ហាទាំងនេះត្រូវបានបង្ហាញនៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដូច្នេះក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ យើងខ្ញុំពុំផ្តល់មតិយោបល់ដាច់ដោយឡែកទៅលើបញ្ហាទាំងនេះឡើយ។

| បញ្ហាសវនកម្មសំខាន់ | នីតិវិធីសវនកម្មរបស់យើងខ្ញុំដើម្បីឆ្លើយតបនឹងបញ្ហាសវនកម្មសំខាន់ |
|---|---|
| ***សំវិធានធនលើការខាតបង់លើឥណទានផ្តល់ដល់អតិថិជន***<br><br>សំដៅទៅ កំណត់សម្គាល់ ៣.៦ សម្រាប់ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត របស់សម្ព័ន្ធធនាគារ និងធនាគារទៅលើឱនភាពនៃតម្លៃឥណទានផ្តល់ដល់អតិថិជន ក្នុងកំណត់សម្គាល់៤ ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ និងការប៉ាន់ស្មានមិនប្រាកដប្រជាហើយ និងកំណត់សម្គាល់ ៣៩.១.១ សម្រាប់ការលាតត្រដាង ការគ្រប់គ្រងហានិភ័យឥណទាន។<br><br>សំវិធានធនលើការខាតបង់រំពឹងទុក (ហៅកាត់ថា "ECL") លើឥណទានផ្តល់ដល់អតិថិជន និងសំវិធានធនចំពោះកិច្ចសន្យាឥណទាន ត្រូវបានចាត់ថាជាបញ្ហាសំខាន់បំផុតដោយសារតែបញ្ហាទាំងនេះត្រូវការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការប្រើប្រាស់ការសន្មតដោយគណៈគ្រប់គ្រងធនាគារ ។<br><br>សម្ព័ន្ធធនាគារ និង ធនាគារអនុវត្តតាម CIFRS៩ "ឧបករណ៍ហិរញ្ញវត្ថុ" ក្នុងឆ្នាំ២០១៩។ CIFRS៩ បានណែនាំអំពី ម៉ូដែលដែលទាមទារឱ្យមានការប្រើប្រាស់ប្រភេទម៉ូដែលស្មុគស្មាញ និងការសន្មតសំខាន់ៗអំពី ឥរិយាបទឥណទាន និងស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត។ ស្តង់ដានេះមានភាពស្មុគស្មាញដែលទាមទារឱ្យ ប្រើប្រាស់ការវិនិច្ឆ័យ និងការបកស្រាយជាច្រើននៅក្នុងការអនុវត្ត។ | ដោយផ្អែកលើការវាយតម្លៃរបស់យើងខ្ញុំ យើងខ្ញុំបានបង្កើតនីតិវិធីសវនកម្ម រួមទាំងការតេស្តលើការគ្រប់គ្រង និងការធ្វើតេស្តសំខាន់ៗជាមូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ។ ដូច្នេះហើយយើងខ្ញុំបានអនុវត្តនីតិវិធីដូចខាងក្រោមក្នុងចំណោមនីតិវិធីដទៃទៀត។<br><br>នីតិវិធីសវនកម្មរបស់យើងខ្ញុំរួមមានដូចខាងក្រោម៖<br><br>• យើងខ្ញុំបានស្វែងយល់ ការវិនិច្ឆ័យទៅលើការបង្កើត និងការអនុវត្ត ព្រមទាំងធ្វើតេស្តលើប្រសិទ្ធភាពប្រតិបត្តិការនៃការត្រួតពិនិត្យគន្លឹះទៅលើសំវិធានធននៃការខាតបង់។ ក្នុងចំណោមការត្រួតពិនិត្យផ្សេងៗការត្រួតពិនិត្យទាំងនេះមានដូចខាងក្រោម៖<br>- បែបបទស្នើសុំប្រាក់កម្ចី និងការពិនិត្យឥណទាន<br>- ការកំណត់នៃការកើនឡើងជាសារវន្តនៃហានិភ័យឥណទាន<br>- ការត្រួតពិនិត្យ ជាបន្តបន្ទាប់ប្រចាំឆ្នាំនៃ លទ្ធភាព និងសមត្ថភាពក្នុងការសងឥណទានរបស់អតិថិជន<br>- ភាពត្រឹមត្រូវនៃការបញ្ចូលទិន្នន័យ<br><br>• យើងខ្ញុំបានវាយតម្លៃថាតើវិធីសាស្ត្រ និងការសន្មតរួមបញ្ចូលនូវសកម្មភាព ការកើនឡើងជាសារវន្តនៃហានិភ័យឥណទាន ដែលបានប្រើប្រាស់ក្នុងម៉ូដែលនៃការខាតបង់ឥណទានដែលរំពឹងទុក មានសង្គតិភាព ជាមួយនឹងការតម្រូវរបស់CIFRSs ការគណនា និងការធ្វើនិយ័តកម្មបន្ទាប់ពីម៉ូដែលECL។<br><br>• យើងខ្ញុំបានធ្វើតេស្តដោយជ្រើសរើសគំរូមួយចំនួនក្នុង ការត្រួតពិនិត្យឥណទានសម្រាប់ការធ្វើចំណាត់ថ្នាក់ និងដំណាក់កាលឥណទាន សួរដេញដោលទៅលើការវាយតម្លៃរបស់គណៈគ្រប់គ្រង និងសន្និដ្ឋានភាពសមរម្យនៃការទទួល |

| **បញ្ហាសវនកម្មសំខាន់** | **នីតិវិធីសវនកម្មរបស់យើងខ្ញុំដើម្បីឆ្លើយតបនឹងបញ្ហាសវនកម្មសំខាន់** |
| --- | --- |
| ការវិនិច្ឆ័យសំខាន់ៗ ក្នុងការអនុវត្តដែលជាការតម្រូវគណនេយ្យសម្រាប់ការវាស់វែង ECL មានដូចខាងក្រោម៖<br>• ការបង្កើតម៉ូដែលវាយតម្លៃជារួម ដែលសមស្រប សម្រាប់ ប្រើប្រាស់ក្នុងការគណនា ECL។ ម៉ូដែលទាំងនេះគឺមានលក្ខណៈស្មុគស្មាញ និងទាមទារការវិនិច្ឆ័យក្នុងការអនុវត្ត ដើម្បីស្ថាបនាម៉ូដែលដែលសាកសម។<br>• កំណត់ជាទៀងទាត់ចំពោះ ឥណទានផ្តល់ដល់អតិថិជន និងហិរញ្ញប្បទាន ដែលធ្លាប់មានការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត។<br>• ការសន្មត ដែលយកមកប្រើប្រាស់ក្នុងម៉ូដែល ECL មានដូចជា លំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគត កត្តាម៉ាក្រូសេដ្ឋកិច្ចរំពឹងទុកនាពេលអនាគត និងសំណុំទិន្នន័យ និង<br>• ការកំណត់ECLបន្ថែម របស់គណៈគ្រប់គ្រងសម្រាប់ឥណទាន ដែលត្រូវបានរៀបចំឡើងវិញ និង សម្រាប់ឥណទានផ្តល់ដល់អតិថិជនស្ថិតក្នុងវិស័យដែលងាយរងគ្រោះ។<br>• និយ័តកម្មបន្ទាប់ពីម៉ូដែល ត្រូវបានកត់ត្រាដោយសម្ព័ន្ធធនាគារ និងធនាគារដោយប្រើការសន្មត និងការវិនិច្ឆ័យរបស់អ្នកជំនាញឥណទាន ដែលធាតុចូល ការសន្មត និង/ឬបច្ចេកទេសម៉ូដែលមិនចាប់យកកត្តាហានិភ័យ ពាក់ព័ន្ធទាំងអស់ទាក់ទងនឹងលក្ខខណ្ឌសេដ្ឋកិច្ច និងស្ថានភាពទីផ្សារបច្ចុប្បន្ន។ | បានឥណទាន ព្រមទាំងចំណាត់ថ្នាក់នៃឥណទានដែលបានជ្រើសរើស។<br>• យើងខ្ញុំបានវាយតម្លៃដំណើរការអនុវត្តរបស់គណៈគ្រប់គ្រងដើម្បីអភិវឌ្ឍព័ត៌មានដែលរំពឹងទុកនៅពេលអនាគត។ យើងខ្ញុំប្រៀបធៀបសូចនាករសំខាន់ៗនៃ ព័ត៌មានដែលរំពឹងទុកនាពេលអនាគាត ទៅនឹងព័ត៌មានដែលបានព្យាករទុកមុនដោយឯករាជ្យ និងព័ត៌មានដែលមានស្រាប់ជាសាធារណៈ។<br>• យើងខ្ញុំបានធ្វើតេស្តទៅលើ ភាពត្រឹមត្រូវនៃការបញ្ចូលទិន្នន័យទៅក្នុងម៉ូដែលECL ដោយបានប្រៀបធៀបទៅប្រភពដើមនៃព័ត៌មាន និងឯកសារផ្សេងៗ។<br>• យើងខ្ញុំបានគណនាឡើងវិញលើសំវិធានធនលើការខាតបង់ឥណទានរំពឹងទុក ដើម្បីត្រួតពិនិត្យនូវភាពត្រឹមត្រូវបែបគណិតវិទ្យានៃម៉ូដែល ECL។<br>• យើងខ្ញុំបានវាយតម្លៃភាពពេញលេញ នៃការលាតត្រដាងដោយ អនុលោមតាមការតម្រូវនៃCIFRS៩។<br>• យើងខ្ញុំ បានសហការជាមួយអ្នកឯកទេសផ្ទៃក្នុង ក្នុងការអនុវត្តនីតិវិធីសវនកម្មទាំងនេះ ដែលជំនាញជាក់លាក់របស់ពួកគេត្រូវបានអនុវត្ត។<br>• ទាក់ទងនឹង លើការធ្វើនិយ័តកម្មបន្ទាប់ពីម៉ូដែល ដោយផ្អែកលើស្ថានការណ៍សេដ្ឋកិច្ចបច្ចុប្បន្ន ឥណទានរៀបចំឡើងវិញ និងសម្រាប់ឥណទានផ្តល់ដល់អតិថិជន ស្ថិតក្នុងវិស័យដែលងាយរងគ្រោះនីតិវិធីរបស់យើងខ្ញុំបានរួមបញ្ចូលការវាយតម្លៃលើការរៀបចំ និងការអនុវត្តដំណើរការត្រួតពិនិត្យផ្ទៃក្នុង។ យើងខ្ញុំបានធ្វើការវាយតម្លៃលើភាពពេញលេញ និងភាពត្រឹមត្រូវនៃការសន្មត ការបញ្ចូលទិន្នន័យ និងការគណនាទៅលើការធ្វើនិយ័តកម្មបន្ទាប់ពីម៉ូដែល រួមជាមួយនឹងការជ្រោមជ្រែងពីអ្នកឯកទេសផ្ទៃក្នុងរបស់យើងខ្ញុំ។ |

Deloitte.

## ព័ត៌មានផ្សេងៗក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករ

គណៈគ្រប់គ្រងទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបង្ហាញនៅទំព័រទី១ ដល់ទី៥ ប៉ុន្តែពុំបានរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំនោះទេ ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ និងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងថានឹងផ្តល់អោយយើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់លើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំពុំបានធ្វើការសន្និដ្ឋានអះអាងលើព័ត៌មានផ្សេងៗនេះឡើយ។

ទាក់ទងនឹងការធ្វើសវនកម្មលើបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺការអានព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗនេះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ឬមានកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ដោយផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ប្រសិនបើព័ត៌មានផ្សេងៗដែលយើងទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍នេះ យើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តអំពីព័ត៌មានផ្សេងៗនេះ យើងខ្ញុំនឹងរាយការណ៍នូវភាពជាក់ស្តែងនោះ។ យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍ឡើយ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋាន ថាមានកំហុសឆ្គងជាសារវន្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍បញ្ហានេះទៅកាន់អ្នកទទួលបន្ទុកអភិបាលកិច្ច។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវដោយអនុលោមទៅតាម CIFRSs និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែល គណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃលើលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម លាតត្រដាងបញ្ហាដែលពាក់ព័ន្ធនឹងការបន្តនិរន្តរភាពប្រសិនបើមាន ដោយការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យ លើកលែងតែគណៈគ្រប់គ្រងមានបំណងរំលាយសម្ព័ន្ធធនាគារ និងធនាគារ ឬបញ្ឈប់អាជីវកម្ម ឬពុំមានជម្រើសជាក់ស្តែងណាមួយក្រៅពីអនុវត្តដូច្នេះ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ។

## ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបានអំណះអំណាងដែលសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល គឺពុំមានកំហុសឆ្គងជាសារវន្ត ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ និងដើម្បីចេញរបាយការណ៍សវនករដែលរួមបញ្ចូលមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់ ប៉ុន្តែពុំមែនជាការធានាថាការធ្វើសវនកម្មដែលអនុលោមតាម CISAs នឹងតែងតែរកឃើញជានិច្ចនូវកំហុសឆ្គងជាសារវន្តដែលបានកើតឡើងនោះទេ។ កំហុសឆ្គងអាចកើតឡើងពីការក្លែងបន្លំ ឬការភាន់ច្រឡំ ហើយត្រូវបានពិចារណាជាកំហុសឆ្គងជាសារវន្ត ប្រសិនបើកំហុសឆ្គងនីមួយៗ ឬរួមបញ្ចូលគ្នា ត្រូវបានរំពឹងថាមានឥទ្ធិពលដល់ការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះជាមូលដ្ឋាន។

Deloitte.

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមតាម CISAs យើងបានធ្វើការវិនិច្ឆ័យ និងរក្សាភាពជឿងឆ្ងល់ប្រកបដោយវិជ្ជាជីវៈ ក្នុងការបំពេញការងារសវនកម្មរបស់យើងខ្ញុំ។ ហើយយើងខ្ញុំបានៈ

- កំណត់ និងវាយតម្លៃលើហានិភ័យនៃកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ដោយរៀបចំ និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងដើម្បីទទួលបានភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមរម្យសម្រាប់ជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលពុំបានរកឃើញកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងហានិភ័យដែលបណ្តាលមកពីការភាន់ច្រឡំដោយសារតែការក្លែងបន្លំអាចបណ្តាលមកពីការឃុបឃិត ការក្លែងឯកសារ ការលុបចោលដោយចេតនា ការថ្លែងខុស ឬការបំពានលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ទទួលបានការយល់ដឹងពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែពុំមែនដើម្បីបញ្ចេញមតិយោបល់ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារឡើយ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងដែលពាក់ព័ន្ធនានាដោយគណៈគ្រប់គ្រងដែលបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រង និងផ្អែកទៅលើភស្តុតាងសវនកម្មដែលបានទទួល ថាតើមានភាពមិនប្រាកដប្រជាជាសារវន្តដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌ ដែលអាចមានការសង្ស័យជាសារវន្តទៅលើលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានភាពមិនប្រាកដប្រជាជាសារវន្ត នោះយើងខ្ញុំត្រូវធ្វើការទាញចំណាប់អារម្មណ៍នៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ ដើម្បីលាតត្រដាងដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមិនគ្រប់គ្រាន់ យើងខ្ញុំត្រូវធ្វើការកែប្រែនៅក្នុងមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ អាស្រ័យលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចបណ្តាលអោយធនាគារបញ្ឈប់ការបន្តនិរន្តរភាពអាជីវកម្ម។
- វាយតម្លៃការបង្ហាញជាទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាង និងថាតើរបាយការណ៍ហិរញ្ញវត្ថុ បង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលពាក់ព័ន្ធ ដើម្បីសម្រេចបាននូវការបង្ហាញដែលត្រឹមត្រូវ។
- ទទួលបាននូវភស្តុតាងសវនកម្មដែលគ្រប់គ្រាន់ និងសមរម្យ ពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុរបស់បណ្តាក្រុមហ៊ុនបុត្រសម្ព័ន្ធ និងសកម្មភាពអាជីវកម្មនៅក្នុងសម្ព័ន្ធធនាគារ ដើម្បីបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុរួម។ យើងខ្ញុំទទួលខុសត្រូវក្នុងការដឹកនាំការត្រួតពិនិត្យ និងការអនុវត្តសវនកម្មរបស់សម្ព័ន្ធធនាគារ។ យើងខ្ញុំនៅតែទទួលខុសត្រូវទាំងស្រុងចំពោះមតិយោបល់សវនកម្មរបស់យើងខ្ញុំ។

**Deloitte.**

យើងខ្ញុំរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ច ពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗ វិសាលភាពការងារ និង ពេលវេលានៃការធ្វើសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្ត ក្នុងការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញក្នុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំក៏បានផ្តល់ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវសេចក្តីអះអាងថា យើងខ្ញុំបានអនុវត្តតាមការតម្រូវផ្នែកក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធនឹងឯករាជ្យភាពព្រមទាំងជូនដំណឹងអំពីទំនាក់ទំនងទាំងអស់ និង បញ្ហាផ្សេងៗ ដែលយើងខ្ញុំយល់ឃើញថាមានផលប៉ះពាល់ចំពោះឯករាជ្យភាពរបស់យើងខ្ញុំ ហើយរួមជាមួយនឹងការអនុវត្តវិធានការនានាដើម្បីលុបបំបាត់នូវការគំរាមកំហែង ឬអនុវត្តនូវវិធីសាស្ត្រការពារ។

ស្តែងចេញពីបញ្ហាដែលយើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ច យើងខ្ញុំកំណត់បញ្ហាទាំងឡាយណាដែលមានផលប៉ះពាល់ខ្លាំងបំផុត ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុក្នុងឆ្នាំបច្ចុប្បន្ន ដូច្នេះបញ្ហានេះជាបញ្ហាសវនកម្មសំខាន់។ យើងខ្ញុំពណ៌នាអំពីបញ្ហាទាំងនេះនៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំលើកលែងតែក្នុងករណីហាមឃាត់ដោយច្បាប់ ឬបទប្បញ្ញត្តិការលាតត្រដាងជាសាធារណៈ ឬលើកលែងតែក្នុងករណីដ៏កម្របំផុតដែលយើងកំណត់ថា បញ្ហាមួយមិនគួរត្រូវបានបង្ហាញក្នុងរបាយការណ៍របស់យើងខ្ញុំទេ ដោយមូលហេតុថា វានឹងអាចមានផលវិបាកអវិជ្ជមាននានា ដែលនាំឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈចំពោះការរាយការណ៍បែបនេះ។

តំណាងក្រុមហ៊ុន ឌីឡយធ៍ (ខេមបូឌា) ខូ អិលធីឌី

អ៊ឹង គឹមសុភ័ក្រ្តា
Partner
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤

## ធនាគារ ហាន្ណា ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | ៨៨.៦៥៧.៨១៤ | ៣៦២.១៦៧.១៧០ | ៦៥.១០៦.១១៧ | ២៦៨.០៩១.៨៨៤ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៥ | ៣៩៨.៥២០.៩០៣ | ១.៦២៧.៩៥៧.៨៨៩ | ២៥៥.៧៦៣.៧៣៣ | ១.០៥២.៩៧៩.២៨៩ |
| សមតុល្យនៅធនាគារនានា | ៦ | ៣៩.៧១៩.៥៩៦ | ១៦២.២៥៤.៥៥០ | ៣៩.៣២២.៨៩៩ | ១៦១.៨៩២.១៦៩ |
| ឥណទានផ្តល់ដល់អតិថិជន | ៧ | ១.៤៦១.៨៨៩.១៦៦ | ៥.៩៧១.៨១៧.២៤៣ | ១.៩០២.៥០៤.៦៩៥ | ៧.៨៣២.៦១១.៨២៩ |
| វិនិយោគលើមូលបត្រ | ៨ | ១៥.៧០៥.២០៨ | ៦៤.១៥៥.៧៧៥ | ១៥.៧០២.៩១៧ | ៦៤.៦៤៨.៩០៩ |
| ឧបករណ៍និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | ១៨ | ១៧.៣៤៣.១៨៦ | ៧០.៨៤៦.៩១៥ | ២១.៩៣២.៣៥៧ | ៩០.២៩៥.៥១៤ |
| ទ្រព្យ និងបរិក្ខារ | ៩ | ៦៣.៣៤៩.១៤៩ | ២៥៨.៧៨១.២៧៤ | ៤៦.៨៥៨.៩៦៧ | ១៩២.៩១៨.៣៦៧ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១០ | ១១.១៩៤.៩៥៨ | ៤៥.៥២៧.១៥៣ | ១១.០៩៨.៨៤៧ | ៤៥.៦៩៣.៩៥៣ |
| ទ្រព្យសកម្មអរូបី | ១១ | ៣.៥៥០.២៨៧ | ១៤.៥០២.៩២២ | ៤.៣៦០.៤០៧ | ១៧.៩៥១.៧៩៦ |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | ១២(ក) | ១៤.៧៣៦.៣៩៥ | ៦០.១៩៧.៨៦៩ | ២.៧៥៨.៣២៣ | ១១.៣៥៦.០១៦ |
| ទ្រព្យសកម្មផ្សេងៗ | ១៣ | ១៥.៥៨២.៧៩២ | ៦៣.៦៥៥.៧០៥ | ២៣.៣៧៧.៤៨៣ | ៩៦.២៤៥.០៩៧ |
| **សរុបទ្រព្យសកម្ម** | | **២.១៣០.១៩៩.៤០៤** | **៨.៧០១.៨៦៤.៥៦៥** | **២.៣៨៨.៧៨៦.៦៩៥** | **៩.៨៣៤.៦៣៤.៨២៣** |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ | ១៤ | ១.១៧៥.៥៧៦.៦៩៧ | ៤.៨០២.២៣០.៨០៧ | ១.១៩២.៧៣១.៥៨៦ | ៤.៩១០.៤៧៥.៩៤០ |
| មូលបត្របំណុល | ១៥ | ៨៣.៤៧៨.១៣១ | ៣៤១.០០៨.១៦៥ | ៤៣.៧២៦.៦៩៩ | ១៨០.០២២.៨២០ |
| ប្រាក់កម្ចី | ១៦ | ៣៩៥.៦៩៣.៦២៥ | ១.៦១៦.៤០៨.៤៥៨ | ៦០៩.២៧០.៩០៨ | ២.៥០៨.៣៦៦.២៧០ |
| អនុបំណុល | ១៧ | ៧២.៧៤៧.៣២៧ | ២៩៧.១៧២.៨៣១ | ៧៤.០១២.៣០២ | ៣០៤.៧០៨.៦៤៧ |
| ឧបករណ៍និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | ១៨ | ២.០៨៧.៤៨០ | ៨.៥២៧.៣៥៦ | ១.៧៣០.០៨៣ | ៧.១២២.៧៥២ |
| បំណុលពន្ធលើប្រាក់ចំណេញ | ១២(ខ) | ២២៥.៤០០ | ៩២០.៧៥៩ | ១៣.៧៦២.២០១ | ៥៦.៦៥៨.៩៨២ |
| បំណុលភតិសន្យា | ១៩ | ១២.០៤៦.៤១៨ | ៤៩.២០៩.៦១៨ | ១២.២៨៦.៨៣០ | ៥០.៥៨៤.៨៧៩ |
| សំវិធានធន | ២០ | ១១.១៩៣ | ៤៥.៧២៣ | ៤.០៦៨ | ១៦.៧៤៨ |
| បំណុលផ្សេងៗ | ២២ | ១៦.០៨៣.៩៣៦ | ៦៥.៧០២.៨៧៨ | ១៩.៧៤៦.៨៥៨ | ៨១.២៩៧.៨១៣ |
| **សរុបបំណុល** | | ១.៧៥៧.៩៥០.២០៧ | ៧.១៨១.២២៦.៥៩៥ | ១.៩៦៧.២៧១.០៣៥ | ៨.០៩៩.២៥៤.៨៥១ |
| **មូលធន** | | | | | |
| ដើមទុន | ២៣ | ១៤០.០០០.០០០ | ៥៧១.៩០០.០០០ | ១៤០.០០០.០០០ | ៥៧៦.៣៨០.០០០ |
| បុព្វលាភភាគហ៊ុន | | ១៩.០៨២.៥០២ | ៧៧.៩៥២.០២១ | ១៩.០៨២.៥០២ | ៧៨.៥៦២.៦៦១ |
| ទុនបម្រុង | ២៤ | ២៩.៣៨៥.០២៨ | ១២៦.៧២៥.១៨០ | ៤៤.៨១៧.៥៤៩ | ១៩៤.៨២៩.០៤០ |
| ទុនបម្រុងដែលមិនត្រូវបែងចែក | ២៥ | ៨០.០០០.០០០ | ៣២៦.៨០០.០០០ | ៧០.០០០.០០០ | ២៨៨.១៩០.០០០ |
| ប្រាក់ចំណេញរក្សាទុក | | ១០៣.៧៨១.៦៦៧ | ៤១៧.២៦០.៧៦៩ | ១៤៧.៦១៥.៦០៩ | ៥៩៧.៤១៨.២៧១ |
| **សរុបមូលធន** | | **៣៧២.២៤៩.១៩៧** | **១.៥២០.៦៣៧.៩៧០** | **៤២១.៥១៥.៦៦០** | **១.៧៣៥.៣៧៩.៩៧២** |
| **សរុបបំណុល និងមូលធន** | | **២.១៣០.១៩៩.៤០៤** | **៨.៧០១.៨៦៤.៥៦៥** | **២.៣៨៨.៧៨៦.៦៩៥** | **៩.៨៣៤.៦៣៤.៨២៣** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# ធនាគារ ហត្ថា ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

# របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលពីការប្រាក់ | ២៦ | ២៥២.៤៥៥.៩៨៥ | ១.០៣៧.៥៩៤.០៩៨ | ២៧៣.៣៣៩.៧៨៧ | ១.១១៧.១៣៩.៧០៩ |
| ចំណាយលើការប្រាក់ | ២៦ | (១១៩.៩៣០.៥១៩) | (៤៩២.៩១៤.៤៣៣) | (១១០.៦៦២.១៨៤) | (៤៥២.២៧៦.៣៤៦) |
| **ចំណូលសុទ្ធពីការប្រាក់** | | **១៣២.៥២៥.៤៦៦** | **៥៤៤.៦៧៩.៦៦៥** | **១៦២.៦៧៧.៦០៣** | **៦៦៤.៨៦៣.៣៦៣** |
| ចំណូលពីកម្រៃនិងជើងសារ | ២៧ | ៥.៦៣៤.៥១១ | ២៣.១៥៧.៨៤០ | ៩.៨៤៩.០២៧ | ៤០.២៥២.៩៧៣ |
| ចំណាយលើកម្រៃនិងជើងសារ | ២៧ | (២.៧២១.៧៦១) | (១១.១៨៦.៤៣៨) | (១.៧១៣.២៥១) | (៧.០០២.០៥៧) |
| **ចំណូលសុទ្ធពីកម្រៃនិងជើងសារ** | | **២.៩១២.៧៥០** | **១១.៩៧១.៤០២** | **៨.១៣៥.៧៧៦** | **៣៣.២៥០.៩១៦** |
| ការចំណេញ/(ខាត)សុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែង តាមFVTPL | ២៨ | ២.៨១៧.៨៣១ | ១១.៥៨១.២៨៥ | (១.០២៥.១៤៦) | (៤.១៨៩.៧៧២) |
| (ខាត)/ចំណូលផ្សេងៗ | ២៩ | (៩៣៩.០១០) | (៣.៨៥៩.៣៣១) | ២២៤.៩៤៥ | ៩១៩.៣៥០ |
| ការខាតបង់សុទ្ធនៃឱនភាពតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ | ៣០ | (១២៤.៦៣៨.៦០៥) | (៥១២.២៦៤.៦៦៧) | (៤.៧១៦.៣៥៣) | (១៩.២៧៥.៧៣៥) |
| ចំណាយលើបុគ្គលិក | ៣១ | (៤៣.៩១៦.៣៨៣) | (១៨០.៤៩៦.៣៣៤) | (៥៣.៤៦៤.៣៧៤) | (២១៨.៥០៨.៨៩៧) |
| ចំណាយរំលស់ និងការខាតបង់នៃឱនភាពតម្លៃ | ៣២ | (៨.៦៦៦.២២១) | (៣៥.៦១៨.១៦៨) | (៦.៤៩៨.១៧៨) | (២៦.៥៥៨.០៥៣) |
| ចំណាយផ្សេងៗ | ៣៣ | (១៤.០៩៤.៧៤៤) | (៥៧.៩២៩.៣៩៨) | (១៣.១៦១.៣៨២) | (៥៣.៧៩០.៥៦៨) |
| **(ខាត)/ប្រាក់ចំណេញមុនដកពន្ធ** | | **(៥៣.៩៩៨.៩១៦)** | **(២២១.៩៣៥.៥៤៦)** | **៩២.១៧២.៨៩១** | **៣៧៦.៧១០.៦០៤** |
| អត្ថប្រយោជន៍/(ចំណាយ)ពន្ធលើប្រាក់ចំណេញ | ១២(គ) | ១០.៤៤៦.២៦៥ | ៤២.៩៣៤.១៥០ | (១៨.៣២៩.២៤០) | (៧៤.៩១១.៦០៤) |
| **(ខាត)/ប្រាក់ចំណេញក្នុងឆ្នាំ** | | **(៤៣.៥៥២.៦៥១)** | **(១៧៩.០០១.៣៩៦)** | **៧៣.៨៤៣.៦៥១** | **៣០១.៧៩៩.០០០** |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| ទុនបម្រុងនៃការការពារលំហូរសាច់ប្រាក់ | | (៧.១៤២.២៦៥) | (២៩.៣៥៤.៧០៩) | ១៨.២៧២.៧១៨ | ៧៤.៦៨០.៥៩៨ |
| ពន្ធលើប្រាក់ចំណេញទាក់ទងនឹងលទ្ធផលលម្អិត ផ្សេងៗ | | ១.៤២៨.៤៥៣ | ៥.៨៧០.៩៤២ | (៣.៦៥៤.៥៤៤) | (១៤.៩៣៦.១២១) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៣.៩២៣.៥៥០) | - | ៦.២៦៥.៣៦៩ |
| | | **(៥.៧១៣.៨១២)** | **(២៧.៤០៧.៣១៧)** | **១៤.៦១៨.១៧៤** | **៦៦.០០៩.៨៤៦** |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | **(៤៩.២៦៦.៤៦៣)** | **(២០៦.៤០៨.៧១៣)** | **៨៨.៤៦១.៨២៥** | **៣៦៧.៨០៨.៨៤៦** |
| **(ខាត)/ប្រាក់ចំណេញផ្ទាល់របស់ភាគទុនិក** | | **(៤៣.៥៥២.៦៥១)** | **(១៧៩.០០១.៣៩៦)** | **៧៣.៨៤៣.៦៥១** | **៣០១.៧៩៩.០០០** |
| **លទ្ធផលលម្អិតសរុបផ្ទាល់របស់ភាគទុនិក** | | **(៤៩.២៦៦.៤៦៣)** | **(២០៦.៤០៨.៧១៣)** | **៨៨.៤៦១.៨២៥** | **៣៦៧.៨០៨.៨៤៦** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# ធនាគារ ហត្ថា ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

## របាយការណ៍បម្រែបម្រួលមូលធនរួម

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | មូលធនផ្ទាល់របស់ភាគទុនិក | | | | | |
|---|---|---|---|---|---|---|
| | ដើមទុន | បុព្វលាភភាគហ៊ុន | ទុនបម្រុង | ទុនបម្រុងដែលមិនត្រូវបែងចែក | ប្រាក់ចំណេញរក្សាទុក | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | | | |
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ១៤០.០០០.០០០ | ១៩.០៨២.៥០២ | ១៤.៨៣០.៨៧២ | ៥០.០០០.០០០ | ១០៩.១៤០.៤៦១ | ៣៣៣.០៥៣.៨៣៥ |
| ការបោះផ្សាយដើមទុនបន្ថែម | - | - | - | - | - | - |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | - | - | ៧៣.៨៤៣.៦៥១ | ៧៣.៨៤៣.៦៥១ |
| លទ្ធផលលម្អិតផ្សេងៗ | - | - | ១៤.៦១៨.១៧៤ | - | - | ១៤.៦១៨.១៧៤ |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | **-** | **-** | **១៤.៦១៨.១៧៤** | **-** | **៧៣.៨៤៣.៦៥១** | **៨៨.៤៦១.៨២៥** |
| ការផ្ទេរ | - | - | ១៥.៣៦៨.៥០៣ | ២០.០០០.០០០ | (៣៥.៣៦៨.៥០៣) | - |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **១៤០.០០០.០០០** | **១៩.០៨២.៥០២** | **៤៤.៨១៧.៥៤៩** | **៧០.០០០.០០០** | **១៤៧.៦១៥.៦០៩** | **៤២១.៥១៥.៦៦០** |
| **សមមូលជាពាន់រៀល** | **៥៧៦.៣៨០.០០០** | **៧៨.៥៦២.៦៦១** | **១៨៤.៨២៩.០៤០** | **២៨៨.១៩០.០០០** | **៥៩៧.៤១៨.២៧១** | **១.៧៣៥.៣៧៩.៩៧២** |
| **ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | |
| **ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ១៤០.០០០.០០០ | ១៩.០៨២.៥០២ | ៤៤.៨១៧.៥៤៩ | ៧០.០០០.០០០ | ១៤៧.៦១៥.៦០៩ | ៤២១.៥១៥.៦៦០ |
| ការបោះផ្សាយដើមទុនបន្ថែម | - | - | - | - | - | - |
| ខាតក្នុងឆ្នាំ | - | - | - | - | (៤៣.៥៥២.៦៥១) | (៤៣.៥៥២.៦៥១) |
| លទ្ធផលលម្អិតផ្សេងៗ | - | - | (៥.៧១៣.៨១២) | - | - | (៥.៧១៣.៨១២) |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | **-** | **-** | **(៥.៧១៣.៨១២)** | **-** | **(៤៣.៥៥២.៦៥១)** | **(៤៩.២៦៦.៤៦៣)** |
| ការផ្ទេរ | - | - | (៩.៧១៨.៧០៩) | ១០.០០០.០០០ | (២៨១.២៩១) | - |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **១៤០.០០០.០០០** | **១៩.០៨២.៥០២** | **២៩.៣៨៥.០២៨** | **៨០.០០០.០០០** | **១០៣.៧៨១.៦៦៧** | **៣៧២.២៤៩.១៩៧** |
| **សមមូលជាពាន់រៀល** | **៥៧១.៩០០.០០០** | **៧៧.៩៥២.០២១** | **១២៦.៧២៥.១៨០** | **៣២៦.៨០០.០០០** | **៤១៧.២៦០.៧៦៩** | **១.៥២០.៦៣៧.៩៧០** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

## ធនាគារ ហាណា ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

## របាយការណ៍លំហូរសាច់ប្រាក់រួម
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់ | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| (ខាត)/ប្រាក់ចំណេញមុនដកពន្ធ | | (៥៣.៩៩៨.៩១៦) | (២២១.៩៣៥.៥៤៦) | ៩២.១៧២.៨៩១ | ៣៧៦.៧១០.៦០៤ |
| *និយ័តភាពលើ៖* | | | | | |
| ចំណូលសុទ្ធពីការប្រាក់ | ២៦ | (១៣២.៥២៥.៤៦៦) | (៥៤៤.៦៧៩.៦៦៥) | (១៦២.៦៧៧.៦០៣) | (៦៦៤.៨៦៣.៣៦៣) |
| ខាត/(ចំណេញ)សុទ្ធពីឧបករណ៍ហិរញ្ញវត្ថុនានា វាស់វែងតាមFVTPL | ២៨ | (២.៨១៧.៨៣១) | (១១.៥៨១.២៨៥) | ១.០២៥.១៤៦ | ៤.១៨៩.៧៧២ |
| ភាគលាភពីការវិនិយោគលើមូលបត្រវាស់វែងតាម FVOCI | | (៥៣.៩២៨) | (២២១.៦៤៤) | (១៥.៥០២) | (៦៣.៣៥៦) |
| ការខាតបង់សុទ្ធនៃឱនភាពតម្លៃលើទ្រព្យសកម្ម ហិរញ្ញវត្ថុ | ៣០ | ១២៤.៦៣៨.៦០៥ | ៥១២.២៦៤.៦៦៧ | ៤.៧១៦.៣៥៣ | ១៩.២៧៥.៧៣៥ |
| ចំណាយរំលស់ និងការខាតបង់នៃឱនភាពតម្លៃ | ៣២ | ៨.៦៦៦.២២១ | ៣៥.៦១៨.១៦៨ | ៦.៤៩៨.១៧៨ | ២៦.៥៥៨.០៥៣ |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | | ១.៥៦៣.៩២១ | ៦.៤២៧.៧១៥ | ១.៩១៧.៦៥០ | ៧.៨៣៧.៤៣៦ |
| ខាត/(ចំណេញ)ពីការលក់ទ្រព្យនិងបរិក្ខារ | | ៦.១០៩ | ២៥.១០៨ | (៩៦.៩៨៥) | (៣៩៦.៣៧៨) |
| ទ្រព្យ និងបរិក្ខារ និងទ្រព្យអរូបីដែលបានលុប ចេញពីបញ្ជី | | ១៦៩.៤៧០ | ៦៩៦.៥២២ | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណធាតុជារូបិយវត្ថុ | | ២.៤១៦.៤៧២ | ៩.៩៣១.៧០០ | ១.៣៨៥.៨៤៨ | ៥.៦៦៣.៩៦១ |
| | | (៥១.៩៣៥.៣៤៣) | (២១៣.៤៥៤.២៦០) | (៥៥.០៧៤.០២៤) | (២២៥.០៨៧.៥៣៦) |
| *បម្រែបម្រួល៖* | | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | | ១២.៧៥៤.០៦៣ | ៥២.៤១៩.១៩៩ | (២៦.៣០៨.០៧២) | (១០៧.៥២១.០៩០) |
| សមតុល្យនៅធនាគារនានា | | (៣១០.៨៤៣) | (១.២៧៧.៥៦៥) | (៣០៧.៦៦២) | (១.២៥៧.៤១៥) |
| ឥណទានផ្តល់ដល់អតិថិជន | | ៣៣០.៥៤៦.០០៨ | ១.៣៥៨.៥៤៤.០៩៣ | (២៥០.៨៤៨.៨៨៨) | (១.០២៥.២១៩.៤០៥) |
| ទ្រព្យសកម្មផ្សេងៗ | | ៥.៣៦២.៨៣៩ | ២២.០៤១.២៦៨ | ២.៤៣១.២៣៧ | ៩.៩៣៦.៤៦៦ |
| ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ | | (២១.៤៣៣.៩៣៤) | (៨៨.០៩៣.៤៦៩) | ១៤៣.០២៧.២៥៦ | ៥៨៤.៥៥២.៣៩៥ |
| បំណុលផ្សេងៗ | | (៣.៦៦២.៩២២) | (១៥.០៥៤.៦០៩) | (៣.៣៥៦.៣៨៩) | (១៣.៧១៧.៣៩៨) |
| សាច់ប្រាក់ទទួលបាន/(ប្រើប្រាស់)ក្នុងប្រតិបត្តិការ | | ២៧១.៣១៩.៨៦៨ | ១.១១៥.១២៤.៦៥៧ | (១៩០.៤៣៦.៥០២) | (៧៧៨.៣១៣.៩៨៣) |
| ការប្រាក់បានទទួល | | ២៣៨.៣៤៦.៧៣៧ | ៩៧៩.៦០៥.០៨៩ | ២៦៧.៦០៤.៣៥៧ | ១.០៩៣.៦៩៩.០០៧ |
| ការប្រាក់បានបង់ | | (១១៣.៥៥៤.៥១៣) | (៤៦៦.៧០៩.០៤៨) | (៩៧.៨៥០.០៣៦) | (៣៩៩.៩១៣.០៩៧) |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១២(ខ) | (១៣.៦៤០.១០៥) | (៥៦.០៦០.៨៣២) | (១៥.៥៤៩.២០៩) | (៦៣.៥៤៩.៦១៧) |
| **សាច់ប្រាក់សុទ្ធទទួលបាន/(ប្រើប្រាស់)ក្នុង សកម្មភាពប្រតិបត្តិការ** | | **៣៨២.៤៧១.៩៨៧** | **១.៥៧១.៩៥៩.៨៦៦** | **(៣៦.២៣១.៣៩០)** | **(១៤៨.០៧៧.៦៩០)** |

## ធនាគារ ហត្ថា ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

## របាយការណ៍លំហូរសាច់ប្រាក់រួម (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់<br>សម្គាល់ | ការិយបរិច្ឆេទដែលបានបញ្ចប់<br>ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទដែលបានបញ្ចប់<br>ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យនិងបរិក្ខារ | ៩ | (២០.៥៩៩.៩០១) | (៨៤.៩៥៨.០៣៨) | (១១.៥៧៧.៥២៧) | (៤៧.៣១៧.៣៥៣) |
| ការទិញទ្រព្យសកម្មអរូបី | ១១ | (២៧២.១៣២) | (១.១១៨.៤៦៣) | (៧០៨.៦១៩) | (២.៨៩៦.១២៦) |
| ការទិញមូលបត្រវិនិយោគ | | - | - | (១៥.០០០.០០០) | (៦១.៣០៥.០០០) |
| សាច់ប្រាក់បានពីការលក់ទ្រព្យនិងបរិក្ខារ | | ៩.២៥៩ | ៣៨.០៥៤ | ១០០.៧៤៨ | ៤១១.៧៥៧ |
| ភាគលាភបានទទួល | | ៥៣.៩២៨ | ២២១.៦៤៤ | ១៥.៥០២ | ៦៣.៣៥៦ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(២០.៧៥៨.៣៤៦)** | **(៨៥.៣១៦.៨០៣)** | **(២៧.១៦៩.៨៩៦)** | **(១១១.០៤៣.៣៦៦)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ៣៤.៣៣៨.៦៥១ | ១៤១.១៣១.៨៥៦ | ៣៤៩.១១៦.៩៤៣ | ១.៤២៦.៨៤០.៩៤៦ |
| សាច់ប្រាក់បានពីការបោះផ្សាយមូលបត្របំណុល | | ៣៨.៣៩៧.៦១៣ | ១៥៧.៦០៨.៦៨៩ | ៣៩.៣៩៧.២៤០ | ១៦១.០១៦.៥២០ |
| សាច់ប្រាក់បានពីអនុបំណុល | | - | - | ៣០.០០០.០០០ | ១២២.៦១០.០០០ |
| ការទូទាត់សងប្រាក់កម្ចី | | (២៤៩.២៣៧.៩៧៣) | (១.០២៤.៣៦៨.០៦៩) | (៣២៧.៧០២.១២៥) | (១.៣៣៩.៣១៨.៥៨៥) |
| ការទូទាត់សងអនុបំណុល | | (២.០០០.០០០) | (៨.២២០.០០០) | (២.០០០.០០០) | (៨.១៧៤.០០០) |
| ការទូទាត់សងប្រាក់ដើមភតិសន្យា | ១០ | (៤.១៧៨.៨១២) | (១៧.១៧៤.៩១៧) | (៤.០៨០.២១៦) | (១៦.៦៧៥.៨៤៣) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់)ក្នុង/ទទួលបានពី សកម្មភាពហិរញ្ញប្បទាន** | | **(១៨២.៧៣០.៥២១)** | **(៧៥១.០២២.៩៤១)** | **៨៤.៧៣១.៨៤២** | **៣៤៦.២៩៩.០៣៨** |
| **ការកើនឡើងសុទ្ធនូវសាច់ប្រាក់ និង សាច់ប្រាក់សមមូល** | | ១៧៨.៩៨៣.១២០ | ៧៣៥.៦២០.៦២២ | ២១.៣៣០.៥៥៦ | ៨៧.១៧៧.៩៨២ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ** | | ១៩៨.៥២៤.២៧៧ | ៨១៧.៣២៤.៤៤៨ | ១៧៧.១៩៣.៧២១ | ៧២១.៨៨៧.២១៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១០.៨២៧.៣៥៣) | - | ៨.២៥៩.២៤៧ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | ៣៤ | **៣៧៧.៥០៧.៣៩៧** | **១.៥៤២.១១៧.៧១៧** | **១៩៨.៥២៤.២៧៧** | **៨១៧.៣២៤.៤៤៨** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

## ធនាគារ ហត្ថា ម.ក

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដាច់ដោយឡែក
# នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | ៨៨.៦៥៧.៨១៤ | ៣៦២.១៦៧.១៧០ | ៦៥.១០៦.១១៧ | ២៦៨.០៩១.៨៨៤ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៥ | ៣៩៨.៥២០.៩០៣ | ១.៦២៧.៩៥៧.៨៨៩ | ២៥៥.៧៦៣.៧៣៣ | ១.០៥២.៩៧៩.២៨៩ |
| សមតុល្យនៅធនាគារនានា | ៦ | ៣៩.៦៦៨.៣២៤ | ១៦២.០៩៥.១០៤ | ៣៩.២៧១.៥៥២ | ១៦១.៦៨០.៩៨០ |
| ឥណទានផ្តល់ដល់អតិថិជន | ៧ | ១.៤៦១.៨៨៩.១៦៦ | ៥.៩៧១.៨១៧.២៤៣ | ១.៩០២.៥០៤.៦៩៥ | ៧.៨៣២.៦១១.៨២៩ |
| វិនិយោគលើមូលបត្រ | ៨ | ១៥.៧០៥.២០៨ | ៦៤.១៥៥.៧៧៥ | ១៥.៧០២.៩១៧ | ៦៤.៦៤៨.៩០៩ |
| វិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ | | ៣.៥០៨.៨៤៤ | ១៤.៣៣៣.៦២៨ | ៣.៥០៨.៨៤៤ | ១៤.៤៤៥.៩១១ |
| ឧបករណ៍និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | ១៨ | ១៧.៣៤៣.១៨៦ | ៧០.៨៤៦.៩១៥ | ២១.៩៣២.៣៥៧ | ៩០.២៩៥.៥១៤ |
| ទ្រព្យនិងបរិក្ខារ | ៩ | ៣៥.៣៧៧.១៤៩ | ១៤៤.៥១៥.៦៥៤ | ១៧.៤២៩.៥២៩ | ៧១.៧៥៧.៣៧១ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១០ | ២១.១៣៤.២៦៦ | ៨៦.៣៣៣.៤៧៧ | ២០.៩២៤.៥៧២ | ៨៦.១៤៦.៤៦៣ |
| ទ្រព្យសកម្មអរូបី | ១១ | ៣.៥៥០.២៨៧ | ១៤.៥០២.៩២២ | ៤.៣៦០.៤០៧ | ១៧.៩៥១.៧៨៦ |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | ១២(ក) | ១៤.១៣៦.១២៤ | ៥៧.៧៤៦.០៦៧ | ២.៤៦៨.៩៦៧ | ១០.១៦៤.៧៣៧ |
| ទ្រព្យសកម្មផ្សេងៗ | ១៣ | ១៥.៦២៥.៥៦៦ | ៦៣.៨៣០.៤៣៦ | ២៣.៨៧៦.២៥០ | ៩៨.២៩៨.៥២១ |
| **សរុបទ្រព្យសកម្ម** | | **២.១១៥.១១៦.៨៣៧** | **៨.៦៤០.២៥២.២៨០** | **២.៣៧២.៨៤៩.៩៤០** | **៩.៧៦៩.០២៣.២០៤** |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ | ១៤ | ១.១៧៦.២០៦.០៩២ | ៤.៨០៤.៨០១.៨៨៦ | ១.១៩៣.៣៥៧.៣២៩ | ៤.៩១៣.០៥២.១២៣ |
| មូលបត្របំណុល | ១៥ | ៨៣.៤៧៨.១៣១ | ៣៤១.០០៨.១៦៥ | ៤៣.៧២៦.៦៩៩ | ១៨០.០២២.៨២០ |
| ប្រាក់កម្ចី | ១៦ | ៣៦៦.១៩២.៩០៦ | ១.៤៩៥.៨៩៨.០២១ | ៥៧៩.៧៦៩.៦៨៩ | ២.៣៨៦.៩១១.៨១០ |
| អនុបំណុល | ១៧ | ៧២.៧៤៧.៣២៧ | ២៩៧.១៧២.៨៣១ | ៧៤.០១២.៣០២ | ៣០៤.៧០៨.៦៤៧ |
| ឧបករណ៍និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ | ១៨ | ២.០៨៧.៤៨០ | ៨.៥២៧.៣៥៦ | ១.៧៣០.០៨៣ | ៧.១២២.៧៥២ |
| បំណុលពន្ធលើប្រាក់ចំណេញ | ១២(ខ) | ១៧១.៣៩៩ | ៧០០.១៦៥ | ១៣.៧១០.១២៧ | ៥៦.៤៤៤.៥៩៣ |
| បំណុលភតិសន្យា | ១៩ | ២២.៩៥៥.៤៩៨ | ៩៣.៧៧៣.២០៩ | ២៣.០៦១.១៤៩ | ៩៤.៩៤២.៧៥០ |
| សំវិធានធន | ២០ | ១១.១៩៣ | ៤៥.៧២៣ | ៤.០៦៨ | ១៦.៧៤៨ |
| កិច្ចសន្យាធានាហិរញ្ញវត្ថុ | ២១ | ២.៥៩៩.៨៦៨ | ១០.៦២០.៤៦១ | ២.៨៩២.៤៣៣ | ១១.៩០៨.១៤៧ |
| បំណុលផ្សេងៗ | ២២ | ១៦.០៧៣.៦៨០ | ៦៥.៦៦០.៩៨៤ | ១៩.៧៣៧.៣១៥ | ៨១.២៥៨.៥២៧ |
| **សរុបបំណុល** | | **១.៧៤២.៥២៣.៥៧៤** | **៧.១១៨.២០៨.៨០១** | **១.៩៥២.០០១.១៩៤** | **៨.០៣៦.៣៨៨.៩១៧** |
| **មូលធន** | | | | | |
| ដើមទុន | ២៣ | ១៤០.០០០.០០០ | ៥៧១.៩០០.០០០ | ១៤០.០០០.០០០ | ៥៧៦.៣៨០.០០០ |
| បុព្វលាភភាគហ៊ុន | | ១៩.០៨២.៥០២ | ៧៧.៩៥២.០២១ | ១៩.០៨២.៥០២ | ៧៨.៥៦២.៦៦១ |
| ទុនបម្រុង | ២៤ | ២៩.៣៨៥.០២៨ | ១២៦.៦៩០.៤៧៦ | ៤៤.៨១៧.៥៤៩ | ១៩៤.៧៩៨.២៦៩ |
| ទុនបម្រុងដែលមិនត្រូវបែងចែក | ២៥ | ៨០.០០០.០០០ | ៣២៦.៨០០.០០០ | ៧០.០០០.០០០ | ២៨៨.១៩០.០០០ |
| ប្រាក់ចំណេញរក្សាទុក | | ១០៤.១២៥.៧៣៣ | ៤១៨.៧០០.៩៨២ | ១៤៦.៩៤៨.៦៩៥ | ៥៩៤.៧០៣.៣៥៧ |
| **សរុបមូលធន** | | **៣៧២.៥៩៣.២៦៣** | **១.៥២២.០៤៣.៤៧៩** | **៤២០.៨៤៨.៧៤៦** | **១.៧៣២.៦៣៤.២៨៧** |
| **សរុបបំណុល និងមូលធន** | | **២.១១៥.១១៦.៨៣៧** | **៨.៦៤០.២៥២.២៨០** | **២.៣៧២.៨៤៩.៩៤០** | **៩.៧៦៩.០២៣.២០៤** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

**ធនាគារ ហត្ថា ម.ក**

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដាច់ដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលពីការប្រាក់ | ២៦ | ២៥២.៤៦៤.៦៧៧ | ១.០៣៧.៦២៩.៨២២ | ២៧៣.៣៣៩.៧៨៧ | ១.១១៧.១៣៩.៧០៩ |
| ចំណាយលើការប្រាក់ | ២៦ | (១២០.១៨៩.៣២៨) | (៤៩៣.៩៧៨.១៣៨) | (១១០.៩០៧.៨៤៤) | (៤៥៣.២៨០.៣៥៨) |
| **ចំណូលសុទ្ធពីការប្រាក់** | | **១៣២.២៧៥.៣៤៩** | **៥៤៣.៦៥១.៦៨៤** | **១៦២.៤៣១.៩៤៣** | **៦៦៣.៨៥៩.៣៥១** |
| ចំណូលពីកម្រៃ និងជើងសារ | ២៧ | ៥.៩២៧.០៧៦ | ២៤.៣៦០.២៨២ | ១០.៤៦៤.៩៤៨ | ៤២.៧៧០.២៤២ |
| ចំណាយលើកម្រៃ និងជើងសារ | ២៧ | (២.៧២១.៧៦១) | (១១.១៨៦.៤៣៨) | (១.៧១៣.២៥១) | (៧.០០២.០៥៧) |
| **ចំណូលសុទ្ធពីកម្រៃ និងជើងសារ** | | ៣.២០៥.៣១៥ | ១៣.១៧៣.៨៤៤ | ៨.៧៥១.៦៩៧ | ៣៥.៧៦៨.១៨៥ |
| ការចំណេញ/(ខាត)សុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL | ២៨ | ២.៨១៧.៨៣១ | ១១.៥៨១.២៨៥ | (១.០២៥.១៤៦) | (៤.១៨៩.៧៧២) |
| (ខាត)/ចំណូលផ្សេងៗ - សុទ្ធ | ២៩ | (៨៨៩.១១២) | (៣.៦៥៤.២៥០) | ២៦៩.៤១៦ | ១.១០១.១០៣ |
| ការខាតបង់សុទ្ធនៃឱនភាពតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ | ៣០ | (១២៤.៦៣៨.៦០៥) | (៥១២.២៦៤.៦៦៧) | (៤.៧១៦.៣៥៣) | (១៩.២៧៥.៧៣៥) |
| ចំណាយលើបុគ្គលិក | ៣១ | (៤៣.៩១១.៦០៦) | (១៨០.៤៧៦.៧០១) | (៥៣.៤៥៨.៨៧២) | (២១៨.៤៨៦.៤១០) |
| ចំណាយរំលស់ | ៣២ | (៧.៥០៩.៨៨៦) | (៣០.៨៦៥.៦៣១) | (៦.៧៥៩.២៥៦) | (២៧.៦២៥.០៧៩) |
| ចំណាយផ្សេងៗ | ៣៣ | (១៤.០៨៩.២៣០) | (៥៧.៩០៦.៧៣៥) | (១៣.១៥៦.៣៦៣) | (៥៣.៧៧០.០៥៦) |
| **(ខាត)/ប្រាក់ចំណេញមុនដកពន្ធ** | | **(៥២.៧៣៩.៩៤៤)** | **(២១៦.៧៦១.១៧១)** | **៩២.៣៣៧.០៦៦** | **៣៧៧.៣៨១.៥៨៧** |
| អត្ថប្រយោជន៍/(ចំណាយ)ពន្ធលើប្រាក់ចំណេញ | ១២(គ) | ១០.១៩៨.២៧៣ | ៤១.៩១៤.៩០២ | (១៨.៤៦៧.៩១៣) | (៧៥.៤៧៨.៣៦០) |
| **(ខាត)/ប្រាក់ចំណេញក្នុងឆ្នាំ** | | **(៤២.៥៤១.៦៧១)** | **(១៧៤.៨៤៦.២៦៩)** | **៧៣.៨៦៩.១៥៣** | **៣០១.៩០៣.២២៧** |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| ទុនបម្រុងនៃការការពារលំហូរសាច់ប្រាក់ | | (៧.១៤២.២៦៥) | (២៩.៣៥៤.៧០៩) | ១៨.២៧២.៧១៨ | ៧៤.៦៨០.៥៩៨ |
| ពន្ធលើប្រាក់ចំណេញទាក់ទងនឹងលទ្ធផលលម្អិត ផ្សេងៗ | | ១.៤២៨.៤៥៣ | ៥.៨៧០.៩៤២ | (៣.៦៥៤.៥៤៤) | (១៤.៩៣៦.១២១) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៤.០៧០.៣២៨) | - | ៦.២៣៦.៣៦២ |
| | | **(៥.៧១៣.៨១២)** | **(២៧.៥៥៤.០៩៥)** | **១៤.៦១៨.១៧៤** | **៦៥.៩៨០.៨៣៩** |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | **(៤៨.២៥៥.៤៨៣)** | **(២០២.៤០០.៣៦៤)** | **៨៨.៤៨៧.៣២៧** | **៣៦៧.៨៨៤.០៦៦** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# ធនាគារ ហត្ថា ម.ក

## របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | មូលធនផ្ទាល់របស់ភាគទុនិក | | | | | |
|---|---|---|---|---|---|---|
| | ដើមទុន | បុព្វលាភភាគហ៊ុន | ទុនបម្រុង | ទុនបម្រុងដែលមិនត្រូវបែងចែក | ប្រាក់ចំណេញរក្សាទុក | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២** | | | | | | |
| **ថ្ងៃទី ១ ខែមករា ឆ្នាំ ២០២២** | ១៤០.០០០.០០០ | ១៩.០៨២.៥០២ | ១៤.៨៣០.៨៧២ | ៥០.០០០.០០០ | ១០៨.៤៤៨.០៤៥ | ៣៣២.៣៦១.៤១៩ |
| ការបោះផ្សាយដើមទុនបន្ថែម | - | - | - | - | - | - |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | - | - | ៧៣.៨៦៩.១៥៣ | ៧៣.៨៦៩.១៥៣ |
| លទ្ធផលលម្អិតផ្សេងៗ | - | - | ១៤.៦១៨.១៧៤ | | - | ១៤.៦១៨.១៧៤ |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | **-** | **-** | **១៤.៦១៨.១៧៤** | | **៧៣.៨៦៩.១៥៣** | **៨៨.៤៨៧.៣២៧** |
| ការផ្ទេរ | - | - | ១៥.៣៦៨.៥០៣ | ២០.០០០.០០០ | (៣៥.៣៦៨.៥០៣) | - |
| **ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២** | **១៤០.០០០.០០០** | **១៩.០៨២.៥០២** | **៤៤.៨១៧.៥៤៩** | **៧០.០០០.០០០** | **១៤៦.៩៤៨.៦៩៥** | **៤២០.៨៤៨.៧៤៦** |
| **សមមូលជាពាន់រៀល** | **៥៧៦.៣៨០.០០០** | **៧៨.៥៦២.៦៦១** | **១៩៩.៧៩៨.២៦៩** | **២៨៨.១៩០.០០០** | **៥៩៩.៧០៣.៣៥៧** | **១.៧៣២.៦៣៤.២៨៧** |
| **ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៣** | | | | | | |
| **ថ្ងៃទី ១ ខែមករា ឆ្នាំ ២០២៣** | ១៤០.០០០.០០០ | ១៩.០៨២.៥០២ | ៤៤.៨១៧.៥៤៩ | ៧០.០០០.០០០ | ១៤៦.៩៤៨.៦៩៥ | ៤២០.៨៤៨.៧៤៦ |
| ការបោះផ្សាយដើមទុនបន្ថែម | - | - | - | - | - | - |
| ខាតក្នុងឆ្នាំ | - | - | - | - | (៤២.៥៤១.៦៧១) | (៤២.៥៤១.៦៧១) |
| លទ្ធផលលម្អិតផ្សេងៗ | - | - | (៥.៧១៣.៨១២) | - | - | (៥.៧១៣.៨១២) |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | **-** | **-** | **(៥.៧១៣.៨១២)** | **-** | **(៤២.៥៤១.៦៧១)** | **(៤៨.២៥៥.៤៨៣)** |
| ការផ្ទេរ | - | - | (៩.៧១៨.៧០៩) | ១០.០០០.០០០ | (២៨១.២៩១) | - |
| **ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៣** | **១៤០.០០០.០០០** | **១៩.០៨២.៥០២** | **២៩.៣៨៥.០២៨** | **៨០.០០០.០០០** | **១០៤.១២៥.៧៣៣** | **៣៧២.៥៩៣.២៦៣** |
| **សមមូលជាពាន់រៀល** | **៥៧១.៩០០.០០០** | **៧៧.៩៥២.០២១** | **១២៦.៦៩០.៤៧៦** | **៣២៦.៨០០.០០០** | **៤១៨.៧០០.៩៨២** | **១.៥២២.០៤៣.៤៧៩** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

## ធនាគារ ហាត្តា ម.ក

# របាយការណ៍លំហូរសាច់ប្រាក់ជាច់ដោយឡែក
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់ | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| (ខាត)/ប្រាក់ចំណេញមុនដកពន្ធ | | (៥២.៧៣៩.៩៤៤) | (២១៦.៧៦១.១៧១) | ៩២.៣៣៧.០៦៦ | ៣៧៧.៣៨១.៥៨៧ |
| *និយ័តភាពលើ៖* | | | | | |
| ចំណូលសុទ្ធពីការប្រាក់ | ២៦ | (១៣២.២៧៥.៣៤៩) | (៥៤៣.៦៥១.៦៨៤) | (១៦២.៤៣១.៩៤៣) | (៦៦៣.៨៥៩.៣៥១) |
| (ចំណេញ)/ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុនានា វាស់វែងតាមFVTPL | ២៨ | (២.៨១៧.៨៣១) | (១១.៥៨១.២៨៥) | ១.០២៥.១៩៦ | ៤.១៨៩.៧៧២ |
| ភាគលាភពីការវិនិយោគលើមូលបត្រវាស់វែងតាម FVOCI | | (៥៣.៩២៨) | (២២១.៦៤៤) | (១៥.៥០២) | (៦៣.៣៥៦) |
| ការខាតបង់សុទ្ធនៃឱនភាពតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ | ៣០ | ១២៤.៦៣៨.៦០៥ | ៥១២.២៦៤.៦៦៧ | ៤.៧១៦.៣៥៣ | ១៩.២៧៥.៧៣៥ |
| ចំណាយរំលស់ | ៣២ | ៧.៥០៩.៨៨៦ | ៣០.៨៦៥.៦៣១ | ៦.៧៥៩.២៥៦ | ២៧.៦២៥.០៧៩ |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | | ១.៥៦៣.៩២១ | ៦.៤២៧.៧១៥ | ១.៩១៧.៦៥០ | ៧.៨៣៧.៤៣៦ |
| ចំណូលពីថ្លៃសេវាធានា | | (២៩២.៥៦៥) | (១.២០២.៤៤២) | (៦១៥.៩២១) | (២.៥១៧.២៦៩) |
| ខាត/(ចំណេញ)ពីការលក់ទ្រព្យនិងបរិក្ខារ | | ៦.១០៩ | ២៥.១០៨ | (៩៦.៩៨៥) | (៣៩៦.៣៧៨) |
| ទ្រព្យនិងបរិក្ខារ និងទ្រព្យអរូបីដែលបានលុបចោល | | ១៦៩.៤៧០ | ៦៩៦.៥២២ | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណធាតុជារូបិយវត្ថុ | | ២.៤១៦.៤៧២ | ៩.៩៣១.៧០០ | ១.៣៨៥.៨៤៨ | ៥.៦៦៣.៩៦១ |
| | | (៥១.៨៧៥.១៥៤) | (២១៣.២០៦.៨៨៣) | (៥៥.០១៩.០៣២) | (២២៤.៨៦២.៧៨៤) |
| *បម្រែបម្រួល៖* | | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | | ១២.៧៥៤.០៦៣ | ៥២.៤១៩.១៩៩ | (២៦.៣០៨.០៧២) | (១០៧.៥២១.០៩០) |
| សមតុល្យនៅធនាគារនានា | | (៣១០.៨៤៣) | (១.២៧៧.៥៦៥) | (៣០៧.៦៦២) | (១.២៥៧.៤១៥) |
| ឥណទានផ្តល់ដល់អតិថិជន | | ៣៣០.៥៩៦.០០៨ | ១.៣៥៨.៥៩៤.០៩៣ | (២៥០.៨៩៨.៨៨៨) | (១.០២៥.២១៩.៤០៥) |
| ទ្រព្យសកម្មផ្សេងៗ | | ៥.៣៦២.៨៣៩ | ២២.០៤១.២៦៨ | ២.៤៣១.២៣៧ | ៩.៩៣៦.៤៦៦ |
| ប្រាក់បញ្ញើរបស់អតិថិជននិងគ្រឹះស្ថានហិរញ្ញវត្ថុ | | (២១.៤៣០.២៨២) | (៨៨.០៧៨.៤៥៩) | ១៤៣.០១៩.៣៧៤ | ៥៨៤.៥២០.១៨២ |
| បំណុលផ្សេងៗ | | (៣.៦៦៣.៦៣៥) | (១៥.០៥៧.៥៤០) | (៣.៣៥៧.២១២) | (១៣.៧២០.៩២៥) |
| សាច់ប្រាក់ទទួលបាន/(ប្រើប្រាស់)ក្នុងប្រតិបត្តិការ | | ២៧១.៣៨២.៩៩៦ | ១.១១៥.៣៨៤.១១៣ | (១៩០.៣៩០.២៥៥) | (៧៧៨.១២៤.៩៧១) |
| | | | | | |
| ការប្រាក់បានទទួល | | ២៣៨.៣០៣.៦៩២ | ៩៧៩.៤២៨.១៧៤ | ២៦៧.៥៦៣.៩១៨ | ១.០៩៣.៥៣៣.៧៣៣ |
| ការប្រាក់បានបង់ | | (១១២.៩៥៧.៣៣២) | (៤៦៤.២៥៤.៦៣៥) | (៩៧.២៥២.៨៥៥) | (៣៩៧.៤៧២.៤១៨) |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១២(ខ) | (១៣.៥៧៩.១៥៩) | (៥៥.៨១០.៣៩៣) | (១៥.៤៨៧.៨៣៩) | (៦៣.២៩៨.៧៩៨) |
| **សាច់ប្រាក់សុទ្ធទទួលបានពី(ប្រើប្រាស់ក្នុង) សកម្មភាពប្រតិបត្តិការ** | | **៣៨៣.១៥០.១៩៧** | **១.៥៧៤.៧៤៧.៣០៩** | **(៣៥.៥៦៧.០៣១)** | **(១៤៥.៣៦២.៤៥៤)** |

## ធនាគារ ហត្ថា ម.ក

# របាយការណ៍លំហូរសាច់ប្រាក់ជាច់ដោយឡែក (ត)
# សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាមេរិក | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពាន់រៀល | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យនិងបរិក្ខារ | ៩ | (២០.៥៤៩.៤០១) | (៨៤.៥៥៨.០៣៨) | (១១.៥៧៧.៥២៧) | (៤៧.៣១៧.៣៥៣) |
| ការទិញទ្រព្យសកម្មអរូបី | ១១ | (២៧២.១៣២) | (១.១១៨.៤៦៣) | (៧០៨.៦១៩) | (២.៨៩៦.១២៦) |
| ការទិញមូលបត្រវិនិយោគ | | - | - | (១៥.០០០.០០០) | (៦១.៣០៥.០០០) |
| សាច់ប្រាក់បានពីការលក់ទ្រព្យនិងបរិក្ខារ | | ៩.២៥៩ | ៣៨.០៥៤ | ១០០.៧៤៨ | ៤១១.៧៥៧ |
| ភាគលាភបានទទួល | | ៥៣.៩២៨ | ២២១.៦៤៤ | ១៥.៥០២ | ៦៣.៣៥៦ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | **(២០.៧៥៨.៣៤៦)** | **(៨៥.៣១៦.៨០៣)** | **(២៧.១៦៩.៨៩៦)** | **(១១១.០៤៣.៣៦៦)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ៣៤.៣៣៨.៦៥១ | ១៤១.១៣១.៨៥៦ | ៣៤៩.១១៦.៩៤៣ | ១.៤២៦.៨៤០.៩៤៦ |
| សាច់ប្រាក់បានពីការបោះផ្សាយមូលបត្របំណុល | | ៣៨.៣៤៧.៦១៣ | ១៥៧.៦០៨.៦៨៩ | ៣៩.៣៩៧.២៤០ | ១៦១.០១៦.៥២០ |
| សាច់ប្រាក់បានពីអនុបំណុល | | - | - | ៣០.០០០.០០០ | ១២២.៦១០.០០០ |
| ការទូទាត់សងប្រាក់កម្ចី | | (២៤៩.២៣៧.៩៧៣) | (១.០២៤.៣៦៨.០៦៩) | (៣២៧.៧០២.១២៥) | (១.៣៣៩.៣១៨.៥៨៥) |
| ការទូទាត់សងអនុបំណុល | | (២.០០០.០០០) | (៨.២២០.០០០) | (២.០០០.០០០) | (៨.១៧៤.០០០) |
| ការទូទាត់សងប្រាក់ដើមភតិសន្យា | ១០ | (៤.៨៥៦.៩៩៧) | (១៩.៩៦២.២៥៨) | (៤.៧៤៤.៥៦០) | (១៩.៣៩១.០១៧) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់)/ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | **(១៨៣.៤០៨.៧០៦)** | **(៧៥៣.៨០៩.៧៨២)** | **៨៤.០៦៧.៤៩៨** | **៣៤៣.៥៨៣.៨៦៤** |
| **ការកើនឡើងសុទ្ធនូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | ១៧៨.៩៨៣.១៤៥ | ៧៣៥.៦២០.៧២៤ | ២១.៣៣០.៥៧១ | ៨៧.១៧៨.០៤៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ** | | ១៩៨.៤៧២.៩៨០ | ៨១៧.១១៣.២៥៩ | ១៧៧.១៤២.៤០៩ | ៧២១.៦៧៨.១៧៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១០.៨២៥.៧១២) | - | ៨.២៥៧.០៤១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | ៣៤ | **៣៧៧.៤៥៦.១២៥** | **១.៥៤១.៩០៨.២៧១** | **១៩៨.៤៧២.៩៨០** | **៨១៧.១១៣.២៥៩** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

## ១. អំពីធនាគារ

ធនាគារ ហត្ថា ម.ក (ហៅកាត់ថា "ធនាគារ") បានប្រែក្លាយពី ក្រុមហ៊ុនហត្ថាកសិករ លីមីតធីត (ហៅកាត់ថា "HKL") ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ហើយទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មធនាគារ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០ និងត្រូវបានអនុម័តការផ្លាស់ប្តូរនេះនៅក្នុងលក្ខន្តិកៈចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ ជាមួយនឹងវិញ្ញាបនប័ត្រអាជីវកម្មលេខ ០០០៥៣៥៥ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ ២០០១ ចេញដោយក្រសួងពាណិជ្ជកម្ម ។

ធនាគារ ត្រូវបានកាន់កាប់ទាំងស្រុងដោយធនាគារ Bank of Ayudhya PLC. (ហៅកាត់ថា "Krungsri") ដែលជាធនាគារចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសថៃ ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦។ ក្រុមហ៊ុនមេរបស់ធនាគារ គឺ MUFG ដែលជាក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសជប៉ុន។

ធនាគារ បានចូលរួមជាចម្បងលើគ្រប់ទិដ្ឋភាពនៃអាជីវកម្មធនាគារ និងការផ្តល់សេវាហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរចំពោះសកម្មភាពសំខាន់ៗទាំងនេះទេក្នុងអំឡុងឆ្នាំ។

ធនាគារ មានប្រតិបត្តិការនៅការិយាល័យចំនួន ១៧១ (រួមបញ្ចូលទាំងការិយាល័យកណ្តាល) ដែលមានទីតាំងនៅរាជធានីភ្នំពេញ និងគ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជា ដោយមានប្រភពចំណូលចម្បងពីការប្រាក់ទទួលបានពីការផ្តល់ឥណទានដល់អតិថិជន។

ធនាគារ មានទីស្នាក់ការកណ្តាល នៅផ្ទះលេខ ៦០៦ ផ្លូវលេខ ២៧១ ភូមិសន្សំកុសល៣ សង្កាត់បឹងទំពុនទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ ហត្ថា សឺវីស ឯ.ក ត្រូវបានចុះបញ្ជីពាណិជ្ជកម្ម នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ ដែលកាន់កាប់ដោយធនាគារ និងក្រុមហ៊ុនសារាយ ហូលឌីង លីមីធីត ដែលជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺការទិញ ការលក់ ការជួល និងការធ្វើអាជីវកម្មអចលនវត្ថុផ្ទាល់ខ្លួន ឬជួលពីគេ។

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤។

## ២. មូលដ្ឋានគណនេយ្យ

### ២.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRSs")។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយផ្អែកលើ មូលដ្ឋានថ្លៃដើមប្រតិបត្តិការ លើកលែងតែឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របនៅរៀងរាល់ការិយបរិច្ឆេទបញ្ចប់នីមួយៗ ដូចដែលបានពន្យល់នៅក្នុងគោលនយោបាយគណនេយ្យខាងក្រោម។

## ២. មូលដ្ឋានគណនេយ្យ (ត)

### ២.២ រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់ការបង្ហាញ

សម្ព័ន្ធធនាគារ និងធនាគារ ធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើរូបិយប័ណ្ណចំនួន៤ គឺប្រាក់រៀល ប្រាក់ដុល្លារអាមេរិក ប្រាក់យ៉េនជប៉ុន និងប្រាក់បាតថៃ។ គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណសម្រាប់ការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសមាសធាតុសេដ្ឋកិច្ចនៃព្រឹត្តិការណ៍មូលដ្ឋាន និងកាលៈទេសៈរបស់សម្ព័ន្ធធនាគារ និងធនាគារ។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។ ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរបាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនោះ។ ធាតុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របនៅក្នុងរូបិយប័ណ្ណបរទេស ត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទដែលតម្លៃសមស្របត្រូវបានកំណត់។ ធាតុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងនៅក្នុងលក្ខខណ្ឌថ្លៃដើមប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេស មិនត្រូវបានប្តូរម្តងទៀតទេ។

ភាពលម្អៀងពីការប្តូររូបិយប័ណ្ណ ដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។

### ២.៣ ការបង្ហាញជារូបិយប័ណ្ណប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពី គណនេយ្យនិងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ការកត់ត្រាប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀលដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រើប្រាស់អត្រាចុងការិយបរិច្ឆេទ និងអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទ ដូចដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជា។

ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗដែលបានបង្ហាញ ត្រូវបានប្តូរតាមអត្រាចុងការិយបរិច្ឆេទនាកាលបរិច្ឆេទនៃរបាយការណ៍ ដោយឡែកខ្ទង់ចំណូល និងចំណាយ នៅក្នុងរបាយការណ៍ ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងខ្ទង់នៅក្នុងលំហូរសាច់ប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រាមធ្យមសម្រាប់ការិយបរិច្ឆេទ ។ លទ្ធផលនៃភាពលម្អៀងទាំងអស់ដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានកត់ត្រាក្នុងចំណូលលម្អិតផ្សេងៗ (ហៅកាត់ថា "OCI")។

## ២. មូលដ្ឋានគណនេយ្យ (ត)

## ២.៣ ការបង្ហាញជារូបិយប័ណ្ណប្រាក់រៀល (ត)

របាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញជាប្រាក់រៀល ត្រូវបានធ្វើឡើងដោយផ្អែកលើអត្រាប្តូរប្រាក់ក្នុងមួយដុល្លារអាមេរិកដូចខាងក្រោម៖

| | អត្រាចុងការិយបរិច្ឆេទ | អត្រាមធ្យម |
|---|---|---|
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៤.០៨៥ | ៤.១១០ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៤.១១៧ | ៤.០៨៧ |

តួលេខដែលត្រូវបានប្តូរនេះ មិនគួរបកស្រាយថាតួលេខនេះជាតួលេខសម្រាប់បង្ហាញដូចតួលេខជាប្រាក់ដុល្លារអាមេរិក ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

តួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្គត់ចំនួនមួយសម្រាប់ប្រាក់ដុល្លាអាមេរិក និងខ្ទង់ពាន់រៀលសម្រាប់ ប្រាក់រៀល។

## ២.៤ មូលដ្ឋាននៃការរួមបញ្ចូលគ្នា

របាយការណ៍ហិរញ្ញវត្ថុរួម រួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានរៀបចំសម្រាប់ដំណាច់ការិយបរិច្ឆេទបញ្ចប់នីមួយៗ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនដែលសម្ព័ន្ធធនាគារមានអំណាចក្នុងការអនុវត្តការគ្រប់គ្រងលើហិរញ្ញវត្ថុ និងគោលនយោបាយប្រតិបត្តិការជំនួញ ដើម្បីទទួលបានផលប្រយោជន៍ពីសកម្មភាពជំនួញ។

ការគ្រប់គ្រងកើតឡើងនៅពេលធនាគារ៖

- មានអំណាចលើក្រុមហ៊ុនដែលបានវិនិយោគ
- មានសិទ្ធិលើប្រាក់ចំណេញបានពីការចូលរួមជាមួយការវិនិយោគ និង
- មានលទ្ធភាពក្នុងការប្រើប្រាស់អំណាចលើការចាត់ចែងប្រាក់ចំណេញ។

ធនាគារវិភាគថាតើខ្លួនមានការគ្រប់គ្រងលើក្រុមហ៊ុនដែលបានវិនិយោគ ប្រសិនបើភាព ជាក់ស្តែង និងស្ថានភាពបង្ហាញថាមានការផ្លាស់ប្តូរកត្តាមួយ ឬច្រើន នៃកត្តាគ្រប់គ្រងទាំងបី ដូចបានរៀបរាប់ខាងលើ។

នៅពេលធនាគារមានសិទ្ធិបោះឆ្នោតតិចជាង សំលេងភាគច្រើនរបស់ក្រុមហ៊ុនដែលបានវិនិយោគ ធនាគារពិចារណាថាតើធនាគារមានអំណាចលើក្រុមហ៊ុនដែលបានវិនិយោគ នៅពេលសិទ្ធិក្នុងការបោះឆ្នោត គឺ មានភាពគ្រប់គ្រាន់ក្នុងការផ្តល់ឱ្យក្រុមហ៊ុននូវលទ្ធភាព ក្នុងការដឹកនាំសកម្មភាពពាក់ព័ន្ធរបស់ក្រុមហ៊ុនដែលបានវិនិយោគ។

## ២. មូលដ្ឋានគណនេយ្យ (ត)

### ២.៤ មូលដ្ឋាននៃការរួមបញ្ចូលគ្នា (ត)

ធនាគារពិចារណាភាពជាក់ស្តែង និងស្ថានភាពពាក់ព័ន្ធ ក្នុងការវិភាគថាតើសិទ្ធិបោះឆ្នោតរបស់ខ្លួនទៅលើក្រុមហ៊ុនដែលបានវិនិយោគ គឺគ្រប់គ្រាន់ក្នុងការផ្តល់អំណាចដល់ខ្លួន ដោយផ្អែកលើកត្តាខាងក្រោម៖

- ទំហំនៃសិទ្ធិបោះឆ្នោតដែលកាន់កាប់ដោយធនាគារ ដែលពាក់ព័ន្ធនឹងទំហំ និងការបែងចែកនៃសិទ្ធិកាន់កាប់របស់អ្នកមានសិទ្ធិបោះឆ្នោតដទៃទៀត
- សក្តានុពលនៃសិទ្ធិបោះឆ្នោតកាន់កាប់ដោយធនាគារអ្នកមានសិទ្ធិបោះឆ្នោត និងភាគីដទៃទៀត
- សិទ្ធបានមកពីការរៀបចំដោយកិច្ចសន្យាដទៃទៀត និង
- ភាពជាក់ស្តែង និងស្ថានភាពបន្ថែមណាមួយ ដែលបញ្ជាក់ថាធនាគារមាន ឬមិនមាន លទ្ធភាពក្នុងការដឹកនាំ សកម្មភាពពាក់ព័ន្ធ នៅពេលដែលតម្រូវឱ្យមានការសម្រេចចិត្ត រួមបញ្ចូលទាំងសិទ្ធក្នុងការបោះឆ្នោតក្នុងការប្រជុំភាគទុនិកពីមុន។

ការរួមបញ្ចូលក្រុមហ៊ុនបុត្រសម្ព័ន្ធចាប់ផ្តើម នៅពេលធនាគារទទួលបានការគ្រប់គ្រងលើ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ហើយបញ្ចប់នៅពេលធនាគារបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ជាពិសេសលទ្ធផលដែលក្រុមហ៊ុនបុត្រសម្ព័ន្ធដែលត្រូវបានទិញ ឬលក់ក្នុងអំឡុងឆ្នាំ ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ ចាប់ពីថ្ងៃដែលធនាគារទទួលបានការគ្រប់គ្រង រហូតដល់កាលបរិច្ឆេទដែលធនាគារបញ្ចប់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

ក្នុងករណីចាំបាច់ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានធ្វើនិយ័តកម្មឱ្យស្របទៅតាមគោលនយោបាយគណនេយ្យរបស់សម្ព័ន្ធធនាគារ។

រាល់អន្តរក្រុមទ្រព្យសកម្ម និង បំណុល មូលធន ចំណូល ចំណាយ និងលំហូរសាច់ប្រាក់ដែលទាក់ទងនឹងប្រតិបត្តិការណ៍រវាងសមាជិករបស់សម្ព័ន្ធធនាគារត្រូវបានលុបបំបាត់ពេលបញ្ចូលរួមគ្នា។

ការផ្លាស់ប្តូរលើការកាន់កាប់ភាគហ៊ុនរបស់សម្ព័ន្ធធនាគារនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមិនធ្វើឱ្យសម្ព័ន្ធធនាគារបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានទទួលស្គាល់ដូចប្រតិបត្តិការមូលធន។ តម្លៃយោងនៃភាគហ៊ុនរបស់សម្ព័ន្ធធនាគារ និងអប្បភាគភាគហ៊ុន ត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្តូរនៃភាគហ៊ុនពាក់ព័ន្ធនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ លម្អៀងណាមួយរវាងចំនួនដែលអប្បភាគភាគហ៊ុនធ្វើនិយ័តកម្ម និងតម្លៃសមស្របនៃទឹកប្រាក់ដែលបានបង់ ឬទទួល គឺត្រូវបានទទួលស្គាល់ដោយផ្ទាល់ចូលក្នុងមូលធន និងទទួលស្គាល់នៅក្នុងម្ចាស់ភាគហ៊ុននៃធនាគារ។

## ២. មូលដ្ឋានគណនេយ្យ (ត)

### ២.៤ មូលដ្ឋាននៃការរួមបញ្ចូលគ្នា (ត)

នៅពេលសម្ព័ន្ធធនាគារបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ប្រាក់ចំណេញឬខាតដែលទទួលស្គាល់នៅក្នុង ចំណេញ ឬខាត និងត្រូវបានគណនាដោយភាពលម្អៀងរវាង (១) តម្លៃសមស្របសរុបនៃទឹកប្រាក់ដែលបានទទួល និងតម្លៃសមស្របនៃភាគហ៊ុនរក្សាទុកណាមួយ (២) តម្លៃដុលពីមុននៃទ្រព្យសកម្ម (រួមទាំងកេរ្តិ៍ឈ្មោះពាណិជ្ជកិច្ច) និងបំណុលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ និងអប្បភាគភាគហ៊ុន។ ចំនួនទាំងអស់ដែលត្រូវបានទទួលស្គាល់ពីមុននៅក្នុងចំណូលលម្អិតផ្សេងទៀត ទាក់ទងនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ គឺត្រូវបានទទួលស្គាល់ដូចដែលសម្ព័ន្ធធនាគារ បានលក់ដោយផ្ទាល់នូវទ្រព្យសកម្ម និងបំណុល នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ (បែងចែកចូលចំណេញ-ខាត ឬផ្ទេរទៅចំណាត់ថ្នាក់ផ្សេងទៀតនៃ មូលធនដូចដែលបានបញ្ជាក់ ឬអនុញ្ញាតដោយ CIFRS)។ តម្លៃសមស្របនៃការវិនិយោគណាមួយ ដែលរក្សានៅក្នុងអតីតក្រុមហ៊ុនបុត្រសម្ព័ន្ធនាកាលបរិច្ឆេទនៅពេលការគ្រប់គ្រងត្រូវបានបាត់បង់ គឺត្រូវបានទទួលស្គាល់ដូចជាតម្លៃសមស្របដែលទទួលស្គាល់ដំបូង សម្រាប់គណនេយ្យបន្តបន្ទាប់ទៀតស្របតាម CIFRS៩ ឬតម្លៃទទួលស្គាល់ដំបូងនៃការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនចូលរួមទុន។

នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារ ការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានវាស់វែងតាមថ្លៃដើមដកបង្គរឱនភាពតម្លៃដែលអាចប្រមូលបានវិញ

ធនាគារកាន់កាប់ភាគហ៊ុនចំនួន៤៩% នៃក្រុមហ៊ុនហត្ថា សឺវីស ឯ.ក ខណៈពេលដែលភាគហ៊ុន ៥១% ទៀត ត្រូវបានកាន់កាប់ដោយក្រុមហ៊ុន សាវាយ ហូលឌីង លីមីធីត។ ទោះបីជាធនាគារមានភាគហ៊ុនតែ ៤៩% នៃហត្ថា សឺវីស ឯ.ក ប៉ុន្តែធនាគារបានវាយតម្លៃថាខ្លួនមានការគ្រប់គ្រងទាំងស្រុងលើក្រុមហ៊ុនបុត្រសម្ព័ន្ធដោយសារការសម្រេចិត្តផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ គឺត្រូវបានចាត់ចែង និងដឹកនាំដោយធនាគារ។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត

ព័ត៌មានគោលនយោបាយគណនេយ្យសារវន្តខាងក្រោមនេះ ត្រូវបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។ គោលនយោបាយទាំងអស់នេះ ត្រូវបានយកមកអនុវត្តប្រកបដោយសង្គតិភាពគ្រប់ការិយបរិច្ឆេទ លើកលែងតែមានការបញ្ជាក់បន្ថែម។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

## ៣.១ ការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូលការប្រាក់ និងចំណាយការប្រាក់ ត្រូវទទួលស្គាល់នៅក្នុងចំណេញ-ខាត ដោយប្រើ វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ អត្រាការប្រាក់ប្រសិទ្ធភាព គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួលតាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះឱ្យមកស្មើនឹង៖

- តម្លៃដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- តម្លៃដករំលស់របស់បំណុលហិរញ្ញវត្ថុ។

ក្នុងការគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ សម្ព័ន្ធធនាគារ និងធនាគារ ធ្វើការប៉ាន់ស្មានលើលំហូរសាច់ប្រាក់នាពេលអនាគត ដោយពិចារណាពល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទានដែលរំពឹងទុកនោះទេ (ECL)។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវកម្រៃទាំងអស់ដែលបានបង់ ឬត្រូវទទួល រវាងភាគីនៃកិច្ចសន្យា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព និងថ្លៃដើមប្រតិបត្តិការ។ ថ្លៃដើមប្រតិបត្តិការ រួមមានការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

**តម្លៃដករំលស់ និងតម្លៃដុល**

តម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់លើកដំបូង ដកការបង់សងប្រាក់ដើមបូកឬដករំលស់បង្គរ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់លើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវកែតម្រូវចំពោះសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ។

តម្លៃដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលធ្វើនិយ័តកម្មលើសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក។

**ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់**

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ជាលើកដំបូង។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានប្រើផ្អែកលើតម្លៃដុលរបស់ទ្រព្យសកម្ម ឬតម្លៃដករំលស់របស់បំណុល។ អត្រាការប្រាក់ប្រសិទ្ធភាព ត្រូវធ្វើការកែប្រែឡើងវិញ ដោយធ្វើការប៉ាន់ស្មានឡើងវិញនូវលំហូរសាច់ប្រាក់របស់ឧបករណ៍ដែលមានអត្រាការប្រាក់ប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### ៣.១ ការប្រាក់ (ត)

ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ (ត)

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានចាត់ទុកថាមានឱនភាពតម្លៃបន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពតម្លៃ នោះការគណនាការប្រាក់ ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានចាត់ទុកថាមានឱនភាពតម្លៃចាប់តាំងពី ទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ដែលបានធ្វើនិយ័តកម្មលើឥណទាន ផ្អែកលើតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ការគណនាការប្រាក់នេះ មិនត្រូវប្តូរទៅផ្អែកលើមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរវិញក៏ដោយ។

### ៣.២ កម្រៃ និងជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារ រួមមានកម្រៃទាំងឡាយណាដែលមិនមែនជាផ្នែកនៃ អត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (សូមមើលកំណត់សម្គាល់លេខ ៣.១)។

ចំណូលកម្រៃ និងជើងសារផ្សេងៗទៀត រួមមានកម្រៃណែនាំ កម្រៃពីការផ្ទេរប្រាក់ កម្រៃលើសេវាគណនីបញ្ញើ កម្រៃផ្សេងៗទៀត និងកម្រៃ និងជើងសារលើសេវាឥណទាន ត្រូវទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។

កិច្ចសន្យាជាមួយអតិថិជន ដែលទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារអាចមានផ្នែកខ្លះនៅក្នុងវិសាលភាពនៃCIFRS ៩ និងផ្នែកខ្លះនៅក្នុងវិសាលភាពនៃ CIFRS ១៥។ ក្នុងករណីនេះ ដំបូងសម្ព័ន្ធធនាគារ និងធនាគារនឹងអនុវត្ត CIFRS ៩ ដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យាដែលមាននៅក្នុងវិសាលភាពនៃ CIFRS ៩ ហើយបន្ទាប់មកអនុវត្ត CIFRS ១៥ លើផ្នែកដែលនៅសល់។

ចំណាយកម្រៃ និងជើងសារផ្សេងៗទៀត ពាក់ព័ន្ធនឹងប្រតិបត្តិការ និងកម្រៃសេវា និងត្រូវទទួលស្គាល់ជាចំណាយនៅពេលបានទទួលសេវាកម្ម។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### ៣.៣ ចំណេញ/ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL

ចំណេញ/ខាតសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុវាស់វែងតាម FVTPL សម្រាប់ឧបករណ៍និស្សន្ទមិនមែនសម្រាប់ការជួញដូរ ដែលត្រូវបានរក្សាទុកសម្រាប់ទប់ស្កាត់ហានិភ័យ ហើយដែលពុំមានលក្ខណៈសម្បត្តិសម្រាប់ទំនាក់ទំនងទប់ស្កាត់ហានិភ័យ (hedging relationship) ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុវាស់វែងតាម FVTPL និងទ្រព្យសកម្មមិនសម្រាប់ការជួញដូរ ដែលវាស់វែងតាម FVTPL។ ធាតុទាំងនេះរួមមានការផ្លាស់ប្តូរតម្លៃសមស្រប អត្រាការប្រាក់ និងលម្អៀងពីការប្តូររូបិយប័ណ្ណ។

### ៣.៤ អត្ថប្រយោជន៍និយោជិត

ប្រាក់រង្វាន់រក្សាទុក

សម្ព័ន្ធធនាគារ និងធនាគារ ផ្តល់អត្ថប្រយោជន៍សម្រាប់រក្សានិយោជិតរបស់ខ្លួន ដែលបានបញ្ចប់រយៈពេលសាកល្បង ដែលជាគម្រោងបង់វិភាគទានកំណត់។ សម្ព័ន្ធធនាគារ និងធនាគារផ្តល់មូលនិធិទៅឱ្យនិយោជិតនីមួយៗជារៀងរាល់ខែ ដោយផ្អែកលើភាគរយនៃប្រាក់បៀវត្សរ៍ប្រចាំខែ ទៅតាមចំនួនឆ្នាំធ្វើការដូចខាងក្រោម៖

| ចំនួនឆ្នាំធ្វើការ | អត្រាប្រចាំខែ |
|---|---|
| រហូតដល់ ៥ ឆ្នាំ | ៦% |
| លើសពី ៥ ឆ្នាំទៅ ១០ ឆ្នាំ | ៨% |
| លើសពី ១០ ឆ្នាំ | ១០% |

ប្រាក់រង្វាន់រក្សាទុក ត្រូវបានរក្សាទុកក្នុងគណនីសន្សំក្រោមឈ្មោះរបស់និយោជិតម្នាក់ៗ ជាមួយនឹងធនាគារ ហើយនឹងត្រូវទូទាត់ជូននិយោជិតនៅពេលដែលនិយោជិតលាឈប់ពីការងារ ស្លាប់ ឬពេលចូលនិវត្តន៍។ នៅពេលលាឈប់ពីការងារ ឬចូលនិវត្តន៍ និយោជិតដែលបានធ្វើការឱ្យធនាគារចាប់ពីបីឆ្នាំឡើងទៅត្រូវបានផ្តល់នូវប្រាក់រង្វាន់រក្សាទុកដែលបង្គរ បូករួមការប្រាក់ទទួលបានក្នុងគណនីសន្សំរបស់ខ្លួន។

កាតព្វកិច្ចក្នុងការបង់ក្នុងគម្រោងវិភាគទាននេះ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មដែលពាក់ព័ន្ធត្រូវបានផ្តល់ឱ្យ និងត្រូវទទួលស្គាល់ជាចំណាយនិយោជិតនៅក្នុងចំណេញ ឬខាត។

**អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី**

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ឱ្យ។ បំណុលត្រូវទទួលស្គាល់តាមចំនួនដែលរំពឹងថាត្រូវបង់ ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬដោយប្រយោល ដើម្បីទូទាត់នូវបំណុលនោះ ដោយសារតែសេវាកម្មផ្តល់ដោយនិយោជិតពីអតីតកាល ហើយកាតព្វកិច្ចនោះត្រូវបានប៉ាន់ស្មានដែលអាចជឿជាក់បាន។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### ៣.៥ ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត លើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬលទ្ធផលលម្អិតផ្សេងៗ។

សម្ព័ន្ធធនាគារ និងធនាគារ បានកំណត់ថាការប្រាក់ និងប្រាក់ពិន័យដែលទាក់ទងនឹងពន្ធលើប្រាក់ចំណេញរួមទាំងពន្ធដែលមិនទាន់ដឹងច្បាស់លាស់ គឺពុំមែនជាពន្ធលើប្រាក់ចំណេញយោងតាមនិយមន័យទេ ដូច្នេះវាត្រូវទទួលស្គាល់តាមស្តង់ដា CIAS ៣៧ *ស្តីពីសំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ* និងត្រូវទទួលស្គាល់ជាចំណាយនៅក្នុងខ្ទង់ "ចំណាយផ្សេងៗ"។

#### ពន្ធប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តមួយភាគធំនាកាលបរិច្ឆេទតារាងតុល្យការ និង និយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗមក។

#### ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះឥណទានពន្ធដែលមិនទាន់បានប្រើ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបានត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីពុំអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ននៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនាកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងពន្ធពន្យារជាទ្រព្យសកម្ម ឆ្លុះបញ្ចាំងនូវពន្ធដែលសម្ព័ន្ធធនាគារ និងធនាគារ រំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល។

ពន្ធពន្យារ និងពន្ធពន្យារជាបំណុល អាចកាត់កងបានតែក្នុងករណី វាបានបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### ៣.៦ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលកិច្ចសន្យាធានាហិរញ្ញវត្ថុ

**ការទទួលស្គាល់ និងការវាស់វែងជាលើកដំបូង**

សម្ព័ន្ធធនាគារ និងធនាគារ បានទទួលស្គាល់ជាលើកដំបូងនូវសមតុល្យនៅធនាគារជាតិនៃកម្ពុជា សមតុល្យនៅធនាគារនានា ឥណទានផ្តល់ដល់អតិថិជន វិនិយោគលើមូលបត្រ ប្រាក់បញ្ញើរបស់អតិថិជននិងគ្រឹះស្ថានហិរញ្ញវត្ថុ មូលបត្របំណុល ឧបករណ៍និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ ប្រាក់កម្ចី អនុបំណុល និងបំណុលភតិសន្យា នាកាលបរិច្ឆេទដែលកើតឡើង។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប រួមបញ្ចូលថ្លៃដើមប្រតិបត្តិការ ដែលកំណត់ថាជាប់ពាក់ព័ន្ធនឹងការទិញ ឬការចេញផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

**ការចាត់ថ្នាក់ និងការវាស់វែងជាបន្តបន្ទាប់**

*ទ្រព្យសកម្មហិរញ្ញវត្ថុ*

នៅក្នុងការទទួលស្គាល់លើកដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ជាតម្លៃដករំលស់ តម្លៃសមស្របតាមរយៈលទ្ធផលលម្អិតផ្សេងៗ ("FVOCI") - ការវិនិយោគបំណុល FVOCI - ការវិនិយោគមូលធន ឬតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL")។

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានចាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់លើកដំបូង លើកលែងតែសម្ព័ន្ធធនាគារ និងធនាគារផ្លាស់ប្តូរម៉ូដែលអាជីវកម្មសម្រាប់គ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ដែលក្នុងករណីនេះ ទ្រព្យសកម្មហិរញ្ញវត្ថុដែលប៉ះពាល់គឺត្រូវបានចាត់ថ្នាក់ម្តងទៀតនៅថ្ងៃដំបូងនៃអំឡុងពេលរាយការណ៍ អនុវត្តតាមការផ្លាស់ប្តូរ ម៉ូដែលអាជីវកម្ម។

ទ្រព្យសកម្មហិរញ្ញវត្ថុមួយ ត្រូវបានវាស់វែងតាមតម្លៃដករំលស់ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុនោះបំពេញ លក្ខខណ្ឌពីរដូចខាងក្រោម៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូឌែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកសម្រាប់ការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (SPPI) តាមចំនួនប្រាក់ដើមដែលនៅជំពាក់តែប៉ុណ្ណោះ។

ឧបករណ៍បំណុល ត្រូវបានវាស់វែងតាម FVOCI លុះត្រាតែវាបានបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូដែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុក ដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

## ៣.៦ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលកិច្ចសន្យាធានាហិរញ្ញវត្ថុ (ត)

ការចាត់ថ្នាក់ និងការវាស់វែងជាបន្តបន្ទាប់ (ត)

*ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)*

- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលជា SPPI។

នៅក្នុងការទទួលស្គាល់ការវិនិយោគលើមូលធនលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ ជួញដូរ សម្ព័ន្ធធនាគារ និងធនាគារអាចជ្រើសរើសក្នុងការបង្ហាញការប្រែប្រួលតម្លៃសមស្របនៅគ្រាបន្ទាប់ក្នុងលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសបែបនេះផ្អែកលើមូលដ្ឋានតាមការវិនិយោគនីមួយៗ។

ទ្រព្យសកម្មទាំងអស់ ដែលមិនត្រូវបានចាត់ថ្នាក់តាមតម្លៃដករំលស់ ឬ FVOCI ដូចបានរៀបរាប់ខាងលើ គឺវាស់វែងតាម FVTPL។ នេះរួមទាំងទ្រព្យសកម្មហិរញ្ញវត្ថុឧបករណ៍និស្សន្ទទាំងឡាយ។ សម្រាប់ការទទួលស្គាល់លើកដំបូង សម្ព័ន្ធធនាគារ និងធនាគារអាចនឹងកំណត់ជាស្ថាពរនូវទ្រព្យសកម្មហិរញ្ញវត្ថុ វាស់វែងតាមFVTPL ប្រសិនបើមិនបំពេញលក្ខខណ្ឌក្នុងការវាស់វែងតាមតម្លៃដករំលស់ ឬតាម FVOCI ប្រសិនបើអនុវត្តដូច្នេះត្រូវលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នា នៃគណនេយ្យដែលនឹងកើតឡើង។

*ការវាយតម្លៃម៉ូឌែលអាជីវកម្ម៖* សម្ព័ន្ធធនាគារ និងធនាគារ វាយតម្លៃគោលបំណងម៉ូឌែលអាជីវកម្មសម្រាប់គ្រប់គ្រងទ្រព្យសកម្មជាសំពៀត ព្រោះវាបានឆ្លុះបញ្ចាំងយ៉ាងល្អបំផុតនូវវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានដល់គណៈគ្រប់គ្រង។ ព័ត៌មានដែលត្រូវយកមកពិចារណារួមមាន៖

- គោលនយោបាយ និងគោលបំណងរបស់សំពៀតរបស់ទ្រព្យសកម្ម និងការអនុវត្តនូវគោលនយោបាយទាំងនោះ។ ជាពិសេស ថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតទៅលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា ការរក្សារនូវទម្រង់អត្រាការប្រាក់ជាក់លាក់ណាមួយ ការផ្គូរផ្គងចិរវេលារបស់ទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹង ចិរវេលារបស់បំណុលដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះទទួលស្គាល់លំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- វិធីក្នុងការវាយតម្លៃ និងរាយការណ៍សំពៀតនៃទ្រព្យសកម្ម ជូនគណៈគ្រប់គ្រងសម្ព័ន្ធធនាគារ និងធនាគារ
- ហានិភ័យដែលប៉ះពាល់ដល់ម៉ូឌែលអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងម៉ូឌែលអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់ទប់ស្កាត់ហានិភ័យទាំងនោះ
- វិធីសាស្ត្រតបស្នងដល់ការគ្រប់គ្រងអាជីវកម្ម (ឧទាហរណ៍ ថាតើការតបស្នងដោយផ្អែកលើតម្លៃសមស្របរបស់ទ្រព្យសកម្មដែលបានគ្រប់គ្រង ឬក៏ផ្អែកលើលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលប្រមូលបាន)
- ភាពញឹកញាប់ ចំនួន និងពេលវេលានៃការលក់ទ្រព្យសកម្មហិរញ្ញវត្ថុនៅអំឡុងពេលមុន មូលហេតុសម្រាប់ការលក់ដូច្នេះ និងការរំពឹងទុកពីសកម្មភាពលក់នាពេលអនាគត។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

## ៣.៦ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលកិច្ចសន្យាធានាហិរញ្ញវត្ថុ (ត)

### ការចាត់ថ្នាក់ និងការវាស់វែងជាបន្តបន្ទាប់ (ត)

*ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)*

ការផ្ទេរនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅភាគីទីបីនៅក្នុងប្រតិបត្តិការ ដែលមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការឈប់ទទួលស្គាល់ គឺមិនត្រូវបានពិចារណាថាលក់សម្រាប់គោលបំណងនេះ សង្គតិភាពជាមួយការទទួលស្គាល់បន្តបន្ទាប់នៃទ្រព្យសកម្មរបស់សម្ព័ន្ធធនាគារ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនប្រើសម្រាប់អាជីវកម្ម ឬមិនត្រូវបានគ្រប់គ្រង និងដែលលទ្ធផលរបស់វាត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប គឺត្រូវបានវាស់វែងតាមFVTPL។

*ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាគឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់៖*

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" មានន័យថា ជាតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលទទួលស្គាល់ជាលើកដំបូង។ "ការប្រាក់" គឺជាការតបសងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលមួយ សម្រាប់ហានិភ័យឥណទានដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេល ជាក់លាក់មួយ និងសម្រាប់ការចំណាយរួមទាំង ហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសន្ទនីយភាព និងចំណាយរដ្ឋបាល) រួមទាំងប្រាក់ចំណេញ។

ដើម្បីវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ សម្ព័ន្ធធនាគារ និងធនាគារ ត្រូវពិចារណាលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ រួមមានការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលអាចធ្វើឱ្យខុសពីលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់។

### ការធ្វើចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានចាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់លើកដំបូងឡើយ លើកលែងតែពេលបន្ទាប់ពីសម្ព័ន្ធធនាគារ ឬធនាគារផ្លាស់ប្តូរម៉ូដែលអាជីវកម្មរបស់ខ្លួនក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

*បំណុលហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារ និងធនាគារចាត់ថ្នាក់បំណុលហិរញ្ញវត្ថុដោយវាស់វែងតាមតម្លៃដករំលស់លើកលែងតែនិស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យដែលត្រូវបានវាស់វែងតាម FVTPL។

*បំណុលកិច្ចសន្យាធានាហិរញ្ញវត្ថុ*

កិច្ចសន្យាធានាហិរញ្ញវត្ថុ គឺជាកិច្ចសន្យាដែលតម្រូវឱ្យអ្នកចេញកិច្ចសន្យាធ្វើការទូទាត់ជាក់លាក់ ដើម្បីទូទាត់សងម្ចាស់បំណុលវិញសម្រាប់ការខាតបង់ដែលកើតឡើងដោយសារកូនបំណុល ដែលមិនបានធ្វើការទូទាត់នៅពេលដល់កំណត់ស្របតាមលក្ខខណ្ឌនៃឧបករណ៍បំណុល។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### ៣.៦ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលកិច្ចសន្យាធានាហិរញ្ញវត្ថុ(ត)

បំណុលកិច្ចសន្យាធានាហិរញ្ញវត្ថុត្រូវបានវាស់វែងជាដំបូងតាមតម្លៃសមស្រប ហើយប្រសិនបើមិនអាចកំណត់ដូចFVTPL និងមិនកើតឡើងពីការផ្ទេរទ្រព្យសម្បត្តិទេ វាត្រូវបានវាស់វែងជាបន្តបន្ទាប់នៅកម្រិតខ្ពស់នៃ

- ការខាតបង់នៃឱនភាពតម្លៃដែលបានកំណត់ដោយអនុលោមតាម CIFRS ៩; និង
- ចំនួនទឹកប្រាក់ដំបូងត្រូវបានទទួលស្គាល់តិចជាងនេះ ហើយទទួលស្គាល់បរិមាណចំណូលសរុបដោយអនុលោមតាមគោលការណ៍នៃ CIFRS ១៥ នៅពេលសមស្រប។

**ការកែប្រែ និងការឈប់ទទួលស្គាល់**

*ទ្រព្យសកម្មហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារ និងធនាគារ ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិតាមកិច្ចសន្យាលើលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុនោះផុតកំណត់។ នៅពេលឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងការតបស្នងដែលបានទទួលត្រូវទទួលស្គាល់ក្នុងចំណេញឬខាត។

ប្រសិនបើលក្ខខណ្ឌរបស់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ សម្ព័ន្ធធនាគារ និងធនាគារ ត្រូវវាយតម្លៃថាតើលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មដែលត្រូវបានកែប្រែនេះ មានភាពខុសគ្នាខ្លាំងដែរ ឬទេ។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំងនោះសិទ្ធិតាមកិច្ចសន្យា ដើម្បីទទួលបានលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដំបូង ត្រូវចាត់ទុកថាផុតកំណត់។ ក្នុងករណីនេះ ត្រូវបញ្ឈប់ការទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុដំបូងនេះ ហើយត្រូវទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុថ្មីតាមតម្លៃសមស្រប បូកថ្លៃដើមប្រតិបត្តិការ។ កម្រៃផ្សេងៗ ដែលបានទទួលពីការកែប្រែនេះ ត្រូវគិតដូចខាងក្រោម៖

- កម្រៃដែលត្រូវយកមកកំណត់តម្លៃសមស្របរបស់ទ្រព្យសកម្មថ្មី ហើយកម្រៃដែលបានមកដោយសារការសងត្រឡប់នូវថ្លៃដើមប្រតិបត្តិការ ត្រូវបញ្ចូលទៅក្នុងការវាស់វែងជាលើកដំបូងរបស់ទ្រព្យសកម្មនោះ។
- កម្រៃផ្សេងៗទៀត ត្រូវបញ្ចូលទៅក្នុងចំណេញឬខាត ជាចំណែកនៃចំណេញ ឬខាត ពីការឈប់ទទួលស្គាល់។

ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែ នៅពេលអ្នកខ្ចីជួបបញ្ហាហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាធម្មតាគឺដើម្បីប្រមូលមកវិញជាអតិបរមានូវលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងការបង្កើតទ្រព្យសកម្មថ្មីជាមួយនឹងលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារ មានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ ដែលនាំឱ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ នោះសម្ព័ន្ធធនាគារ និងធនាគារដំបូងត្រូវពិចារណាថាតើផ្នែកណាមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចោល មុនពេលធ្វើការកែប្រែ (សូមមើលគោលនយោបាយសម្រាប់ការលុបចេញពីបញ្ជី)។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### ៣.៦ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលកិច្ចសន្យាធានាហិរញ្ញវត្ថុ(ត)

**ការកែប្រែ និងការឈប់ទទួលស្គាល់ (ត)**

*ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)*

វិធីសាស្ត្រនេះជះឥទ្ធិពលដល់ លទ្ធផលនៃការវាយតម្លៃតាមបរិមាណ និងមធ្យោបាយដែលលក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ជាធម្មតាមិនត្រូវបានអនុវត្ត នៅក្នុងករណីបែបនេះទេ។

ប្រសិនបើការប្រែទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់ ឬ FVOCI មិនមានគុណវុឌ្ឍិសម្រាប់ការឈប់ទទួលស្គាល់ទេនោះ សម្ព័ន្ធធនាគារ និងធនាគារ ត្រូវធ្វើការគណនាតម្លៃដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុនោះឡើងវិញ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពពីដំបូងរបស់ទ្រព្យសកម្មនោះ និងត្រូវទទួលស្គាល់ជាចំណេញឬខាតពីការកែប្រែ នៅក្នុងចំណេញ-ខាត។ រាល់ចំណាយ និងកម្រៃផ្សេងៗដែលបានកើតឡើង ត្រូវកែតម្រូវជាមួយតម្លៃដុល និងត្រូវដករំលស់តាមរយៈពេលនៅសល់របស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ។

ប្រសិនបើការកែប្រែនេះ ធ្វើឡើងដោយសារតែបញ្ហាស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី នោះចំណេញឬខាត ត្រូវបង្ហាញរួមជាមួយនឹងការខាតបង់លើឱនភាពតម្លៃ។ ករណីផ្សេងពីនេះ ត្រូវបង្ហាញជាចំណូលការប្រាក់ដែលគណនាតាមវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

*បំណុលហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារ និងធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចបានចែងក្នុងកិច្ចសន្យាត្រូវបានលុបចោល ឬត្រូវបានបោះបង់ចោល ឬផុតកំណត់។

សម្ព័ន្ធធនាគារ និងធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌត្រូវបានកែប្រែ ហើយលំហូរសាច់ប្រាក់របស់បំណុលដែលបានកែប្រែមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ ត្រូវទទួលស្គាល់បំណុលហិរញ្ញវត្ថុថ្មីតាមតម្លៃសមស្រប ដោយផ្អែកលើលក្ខខណ្ឌដែលបានកែប្រែ។ ភាពខុសគ្នារវាងតម្លៃយោងរបស់បំណុលហិរញ្ញវត្ថុដែលឈប់ទទួលស្គាល់ និងទឹកប្រាក់ដែលបានបង់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញឬខាត។

ប្រសិនបើការប្រែបំណុលហិរញ្ញវត្ថុនេះមិនមានគុណវុឌ្ឍិសម្រាប់ការឈប់ទទួលស្គាល់ទេ នោះតម្លៃដករំលស់របស់បំណុល ត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពពីដំបូង ហើយចំណេញឬខាតពីការគណនានេះ ត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត។ ចំពោះបំណុលហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ប្រែប្រួល អត្រាការប្រាក់ប្រសិទ្ធភាពពីដំបូង ដែលត្រូវបានយកមកប្រើដើម្បីធ្វើការគណនា ចំណេញឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារនៅពេលកែប្រែ។ រាល់ការចំណាយ និងកម្រៃផ្សេងៗ ដែលបានកើតឡើង ត្រូវទទួលស្គាល់ជាការកែតម្រូវចំពោះតម្លៃយោងរបស់បំណុល និងត្រូវដករំលស់តាមរយៈពេលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែប្រែ ដោយធ្វើការគណនាឡើងវិញនូវអត្រាការប្រាក់ប្រសិទ្ធភាពនៃឧបករណ៍នោះ។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### ៣.៦ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលកិច្ចសន្យាធានាហិរញ្ញវត្ថុ(ត)

**ការកាត់កង**

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែសម្ព័ន្ធធនាគារ និងធនាគារ មានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នា និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ចំណូល និងចំណាយអាចត្រូវបានបង្ហាញដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធបាន លុះត្រាតែមានការអនុញ្ញាតនៅក្នុង CIFRS ឬអាចធ្វើទៅបាន ចំពោះចំណេញ ឬខាត ដែលកើតចេញពីក្រុមប្រតិបត្តិការដែលមានលក្ខណៈស្រដៀងគ្នា។

**ការវាស់វែងតម្លៃសមស្រប**

"តម្លៃសមស្រប" គឺជាថ្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬថ្លៃដែលបានសងចំពោះការផ្ទេរបំណុល នៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអទិភាពបំផុត ដែលសម្ព័ន្ធធនាគារ និងធនាគារ អាចកំណត់បាននាកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យដែលមិនដំណើរការ។

សម្ព័ន្ធធនាគារ និងធនាគារ វាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ។ ទីផ្សារមួយចាត់ទុកថាជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុលកើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់។ ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេនោះ សម្ព័ន្ធធនាគារ និងធនាគារ ត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចបង្កើននូវការប្រើប្រាស់ធាតុចូលដែលអាចសង្កេតបាន និងកាត់បន្ថយនូវការប្រើប្រាស់ធាតុចូលដែលមិនអាចសង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសយកមកប្រើប្រាស់ ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់ថ្លៃ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាថ្លៃប្រតិបត្តិការ មានន័យថាជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឱ្យ ឬបានទទួល។ ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារ កំណត់ថាតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីថ្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះ ពុំមានភស្តុតាងមកបញ្ជាក់តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះធាតុចូលដែលមិនអាចសង្កេតបានពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មតថាមិនធំដុំ ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នា រវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងថ្លៃប្រតិបត្តិការ។ ជាបន្តបន្ទាប់មកទៀតភាពខុសគ្នានោះ គឺត្រូវទទួលស្គាល់នៅក្នុងចំណេញ-ខាត ផ្អែកលើមូលដ្ឋានអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឱ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលចប់ប្រតិបត្តិការនោះទេ។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

## ៣.៦ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលកិច្ចសន្យាធានាហិរញ្ញវត្ថុ (ត)

### តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុរួមមានទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងឧបករណ៍ហិរញ្ញវត្ថុក្រៅរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ព័ត៌មានដែលបានបង្ហាញនៅទីនេះ តំណាងឱ្យការប៉ាន់ស្មាននៃតម្លៃសមស្របនាកាលបរិច្ឆេទនៃស្ថានភាពហិរញ្ញវត្ថុ។

តម្លៃទីផ្សារដែលបានដកស្រង់ និងអាចសង្កេតបាន ហើយអាចរកបាន ត្រូវបានប្រើសម្រាប់វាស់វែងលើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ។ នៅពេលដែលតម្លៃទីផ្សារដែលបានដកស្រង់ និងអាចសង្កេតបានមិនអាចប្រើប្រាស់បាន នោះតម្លៃសមស្របត្រូវបានប៉ាន់ស្មានដោយផ្អែកលើវិធីសាស្ត្រ និងការសន្មតជាច្រើនទាក់ទងទៅនឹងលក្ខណៈហានិភ័យនៃឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ អត្រាអប្បហារ ការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់នាពេលអនាគត និងកត្តាផ្សេងៗទៀត។

ព័ត៌មាននៃតម្លៃសមស្របសម្រាប់ទ្រព្យសកម្ម និងបំណុលមិនមែនហិរញ្ញវត្ថុ មិនត្រូវបានរាប់បញ្ចូលទេពីព្រោះវាមិនស្ថិតក្នុងវិសាលភាពនៃ CIFRS ៧៖ *ការបង្ហាញឧបករណ៍ហិរញ្ញវត្ថុ* ដែលទាមទារឱ្យមានការបង្ហាញព័ត៌មាននៃតម្លៃសមស្រប។ នេះរួមបញ្ចូលទាំងការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ និងការវិនិយោគទ្រព្យ និង បរិក្ខារ។

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារមានដូចជាសាច់ប្រាក់ និងមូលធនរយៈពេលខ្លី សមតុល្យនៅធនាគារជាតិនៃកម្ពុជា ប្រាក់បញ្ញើជាមួយធនាគារ និងគ្រឹះស្ថាន ហិរញ្ញវត្ថុនានា ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ទ្រព្យសកម្មផ្សេងៗ បំណុល ផ្សេងៗ និងកម្ចីរយៈពេលខ្លី គឺមិនមានលក្ខណៈជាសារវន្ត ចំពោះការផ្លាស់ប្តូរអត្រាប្រាក់ចំណេញក្នុងទីផ្សារ ដោយសារតែឧបករណ៍ហិរញ្ញវត្ថុទាំងនេះមានរយៈពេលកំណត់ជាក់លាក់។ តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុទាំងនេះ នៅកាលបរិច្ឆេទរាយការណ៍មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា។

### ឋានានុក្រមតម្លៃសមស្រប

CIFRS ៧ បញ្ជាក់ពីចំណាត់ថ្នាក់នៃបច្ចេកទេសវាយតម្លៃដោយផ្អែកលើ ថាតើទិន្នន័យនៃបច្ចេកទេសវាយតម្លៃទាំងនោះអាចសង្កេតបាន ឬមិនអាចសង្កេតបាន។ ទិន្នន័យដែលអាចសង្កេតបានឆ្លុះបញ្ចាំងពីទិន្នន័យទីផ្សារដែលទទួលបានពីប្រភពឯករាជ្យ និងទិន្នន័យដែលមិនអាចសង្កេតបានឆ្លុះបញ្ចាំងពីការសន្មតទីផ្សាររបស់សម្ព័ន្ធធនាគារ និងធនាគារ។ ចំណាត់ថ្នាក់នៃតម្លៃសមស្របមានដូចខាងក្រោម៖

កម្រិតទី ១៖ តម្លៃដកស្រង់ (មិនបានធ្វើនិយ័តភាព) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា ។ កម្រិតនេះរាប់បញ្ចូលទាំងមូលបត្រកម្មសិទ្ធិដែលបានចុះបញ្ជី និងឧបករណ៍បំណុល។

កម្រិតទី២៖ ទិន្នន័យក្រៅពីតម្លៃដែលបានដកស្រង់រាប់បញ្ចូលក្នុងកម្រិតទី១ ដែលអាចសង្កេតបានចំពោះទ្រព្យសកម្ម ឬបំណុល ដោយផ្ទាល់ (ឧទាហរណ៍៖ តម្លៃ) ឬដោយប្រយោល (ឧទាហរណ៍៖ កើតចេញពីតម្លៃ)។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

## ៣.៦ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

### ឋានានុក្រមតម្លៃសមស្រប (ត)

កម្រិតទី៣៖ ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចសង្កេតបាន (ធាតុចូលដែលមិនអាចសង្កេតបាន)។ កម្រិតនេះរួមបញ្ចូលទាំងឧបករណ៍មូលធន និងឧបករណ៍បំណុល ដែលមានសមាសធាតុមិនអាចសង្កេតបានជាសារវន្ត។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍៖ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់។

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្របនៅចុងការិយបរិច្ឆេទបញ្ចប់នៃរបាយការណ៍ពេលដែលការផ្លាស់ប្តូរបានកើតឡើង។

### ឱនភាពតម្លៃ

សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលរំពឹងទុក ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃដករំលស់៖ ត្រូវបង្ហាញជាការដកចេញ ពីតម្លៃដុលរបស់ទ្រព្យសកម្មនោះ និង
- កិច្ចសន្យាឥណទាន៖ ជាទូទៅ ត្រូវបង្ហាញជាសំវិធានធន។

ចំពោះគោលនយោបាយលម្អិតទាក់ទងនឹងឱនភាពតម្លៃ សូមមើលកំណត់សម្គាល់លេខ ៣៩.១.៤។

### ការលុបចេញពីបញ្ជី

ឥណទានត្រូវបានលុបចេញពីបញ្ជីទាំងស្រុង នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវ ទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង។ ករណីនេះមានជាទូទៅ នៅពេលសម្ព័ន្ធធនាគារ និងធនាគារកំណត់ថាអតិថិជន ពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួន ដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្ម
នីមួយៗ។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់នៅក្នុងចំណេញឬខាត។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី នៅតែតម្រូវឱ្យមានសកម្មភាពទាមទារសងមកវិញដើម្បី អនុលោមតាមនីតិវិធីរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការប្រមូលទឹកប្រាក់នៅជំពាក់។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

## ៣.៧ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យដែលមិនមានការកំហិតនៅធនាគារជាតិនៃកម្ពុជា និងទ្រព្យសកម្មហិរញ្ញវត្ថុសន្ទនីយភាព ដែលមានកាលវសាន្តរយៈពេលបីខែ ឬតិចជាងចាប់ពីកាលបរិច្ឆេទទិញ និងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ហើយដែលសម្ព័ន្ធធនាគារ និងធនាគារ ប្រើដើម្បីបំពេញកាតព្វកិច្ចសន្យារយៈពេលខ្លី។

## ៣.៨ ឧបករណ៍និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ

### និស្សន្ទសម្រាប់គោលបំណងទប់ស្កាត់ហានិភ័យ និងគណនេយ្យទប់ស្កាត់ហានិភ័យ

និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ រួមមានទ្រព្យសកម្ម និងបំណុលនិស្សន្ទទាំងអស់ ដែលមិនត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្ម ឬបំណុលសម្រាប់ការជួញដូរ។ និស្សន្ទត្រូវបានវាស់វែងតាមតម្លៃសមស្របនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

សម្ព័ន្ធធនាគារ និងធនាគារ កំណត់សនិស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យជាឧបករណ៍ទប់ស្កាត់ហានិភ័យ ក្នុងការបំពេញទំនាក់ទំនងទប់ស្កាត់ហានិភ័យ។

### គោលនយោបាយអនុវត្តទូទៅចំពោះទំនាក់ទំនងទប់ស្កាត់ហានិភ័យ

ពេលកំណត់ការទប់ស្កាត់ហានិភ័យលើកដំបូង សម្ព័ន្ធធនាគារ និងធនាគារកត់ត្រាឯកសារទំនាក់ទំនងរវាងឧបករណ៍ទប់ស្កាត់ហានិភ័យនិងធាតុទប់ស្កាត់ហានិភ័យ រួមមានកម្មវត្ថុគ្រប់គ្រងហានិភ័យ និងយុទ្ធសាស្ត្រក្នុងការ ទប់ស្កាត់ហានិភ័យ ជាមួយវិធីសាស្ត្រ ដែលនឹងត្រូវបានប្រើប្រាស់ក្នុងការវាយតម្លៃប្រសិទ្ធិភាពនៃទំនាក់ទំនងទប់ស្កាត់ហានិភ័យ។ សម្ព័ន្ធធនាគារ និងធនាគារវាយតម្លៃទំនាក់ទំនងទប់ស្កាត់ហានិភ័យនៅពេលចាប់ផ្តើម និងមូលដ្ឋានបន្តបន្ទាប់ទៀត ថាតើឧបករណ៍ទប់ស្កាត់ហានិភ័យត្រូវបានរំពឹងទុកថាមានប្រសិទ្ធិភាពខ្ពស់ ក្នុងការកាត់កងការផ្លាស់ប្តូរលើតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នៃធាតុទប់ស្កាត់ហានិភ័យក្នុងអំឡុងពេលដែលការទប់ស្កាត់ហានិភ័យ ត្រូវបានកំណត់ដែរឬទេ។ សម្រាប់ការទប់ស្កាត់លំហូរសាច់ប្រាក់នៃប្រតិបត្តិការដែលព្យាករណ៍ទុក សម្ព័ន្ធធនាគារ និងធនាគារធ្វើការវាយតម្លៃថាតើប្រតិបត្តិការដែលព្យាករណ៍ទុកគឺអាចកើតឡើងភាគច្រើន និងបង្ហាញភាពខុសគ្នានៅក្នុងលំហូរសាច់ប្រាក់ដែលអាចប៉ះពាល់ដល់ចំណេញឬខាត។

សម្ព័ន្ធធនាគារ និងធនាគារជាញឹកញាប់កំណត់ផ្នែកលំហូរសាច់ប្រាក់នៃឧបករណ៍ហិរញ្ញវត្ថុសម្រាប់លំហូរសាច់ប្រាក់ ឬការផ្លាស់ប្តូរតម្លៃសមស្រប ពាក់ព័ន្ធនឹងមូលដ្ឋានហានិភ័យអត្រាការប្រាក់ ប្រសិនបើផ្នែកនោះគឺត្រូវបានកំណត់ដាច់ដោយឡែក និងវាយតម្លៃជាក់លាក់។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត((ត)

### ៣.៨ និស្សន្ទសម្រាប់ទប់ស្កាត់ហានិភ័យ (ត)

ការទប់ស្កាត់លំហូរសាច់ប្រាក់

នៅពេលនិស្សន្ទត្រូវបានកំណត់ជាឧបករណ៍ទប់ស្កាត់ហានិភ័យ នៅក្នុងការទប់ស្កាត់ហានិភ័យខុសៗគ្នា នៅក្នុងលំហូរសាច់ប្រាក់ពាក់ព័ន្ធនឹងហានិភ័យជាក់លាក់មួយ ទាក់ទងនឹងទ្រព្យសកម្ម ឬបំណុលដែលទទួលស្គាល់ ឬប្រតិបត្តិការព្យាករណ៍ថាកើតឡើងខ្ពស់ ដែលអាចប៉ះពាល់ដល់ចំណេញឬខាត ផ្នែកដែលមានប្រសិទ្ធិភាពនៃការ ផ្លាស់ប្តូរលើតម្លៃសមស្របនៃនិស្សន្ទត្រូវបានទទួលស្គាល់ក្នុង OCI និងបង្ហាញនៅក្នុងទុនបម្រុងទប់ស្កាត់ហានិភ័យក្នុងមូលធន។ ផ្នែកដែលមិនមានប្រសិទ្ធិភាពណាមួយនៃការផ្លាស់ប្តូរលើតម្លៃសមស្របនៃនិស្សន្ទត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត។ ចំនួនដែលទទួលស្គាល់នៅក្នុងទុនបម្រុងទប់ស្កាត់ហានិភ័យត្រូវបានចាត់ថ្នាក់ពី OCI ទៅចំណេញ ឬខាត ដូចការកែតម្រូវការចាត់ថ្នាក់ឡើងវិញ ក្នុងអំឡុងពេលដូចគ្នានឹងពេលលំហូរសាច់ប្រាក់ទប់ស្កាត់ ហានិភ័យប៉ះពាល់ដល់ចំណេញ ឬខាត និងមានធាតុដូចគ្នានៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។

ធនាគារមិនបន្តគណនេយ្យទប់ស្កាត់ហានិភ័យនៅពេលដែលទំនាក់ទំនងទប់ស្កាត់ហានិភ័យ (ឬផ្នែកណាមួយ) មិនគ្រប់លក្ខណៈវិនិច្ឆ័យគុណវុឌ្ឍិ (បន្ទាប់ពីធ្វើតុល្យភាពឡើងវិញ បើមាន)។ នេះរួមបញ្ចូលករណីនៅពេលឧបករណ៍ទប់ស្កាត់ហានិភ័យផុតកំណត់ ឬត្រូវបានលក់ បញ្ឈប់ ឬអនុវត្ត។ ការមិនបន្តគឺត្រូវទទួលស្គាល់ជាការអនុវត្តទៅមុខ។

ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើនិស្សន្ទត្រូវបានជំនួសនូវភាគីកណ្តាល ដោយភាគីទាំងពីរដោយសារច្បាប់ ឬ បទប្បញ្ញត្តិ ដោយគ្មានការផ្លាស់ប្តូរលក្ខខណ្ឌ លើកលែងតែចំណែកដែលចាំបាច់ត្រូវជំនួស នោះនិស្សន្ទមិនត្រូវបានពិចារណាថាផុតកំណត់ ឬបញ្ឈប់។ ប្រសិនបើការទប់ស្កាត់លំហូរសាច់ប្រាក់មិនរំពឹងថាកើតឡើងទៀត នោះសម្ព័ន្ធធនាគារ និងធនាគារចាត់ថ្នាក់ឡើងវិញភ្លាមៗនូវចំនួននៅក្នុងទុនបម្រុងទប់ស្កាត់ហានិភ័យពីOCI ទៅចំណេញ ឬខាត។ សម្រាប់ទំនាក់ទំនងទប់ស្កាត់ហានិភ័យដែលបញ្ឈប់ ប្រសិនបើលំហូរសាច់ប្រាក់ដែលទប់ស្កាត់ហានិភ័យនៅតែរំពឹងថាកើតឡើង នោះចំនួនបង្គរនៅក្នុងទុនបម្រុងទប់ស្កាត់ហានិភ័យមិនត្រូវបានចាត់ថ្នាក់ម្តងទៀតទេ រហូតដល់លំហូរសាច់ប្រាក់ដែលទប់ស្កាត់ហានិភ័យប៉ះពាល់ដល់ចំណេញ ឬខាត។ ប្រសិនបើលំហូរសាច់ប្រាក់ទប់ស្កាត់ហានិភ័យត្រូវបានរំពឹងថាប៉ះពាល់ចំណេញ ឬខាត នៅក្នុងពហុអំឡុងពេលរាយការណ៍ នោះសម្ព័ន្ធធនាគារ និងធនាគារចាត់ថ្នាក់ម្តងទៀតនូវចំនួននៅក្នុងទុនបម្រុងទប់ស្កាត់ហានិភ័យពីOCI ទៅចំណេញ ឬខាតតាម មូលដ្ឋានរំលស់ថេរ។

### ៣.៩ ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជនដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺជាឥណទានដែលវាស់វែងតាមតម្លៃដករំលស់។ ឥណទានទាំងនោះ ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកនឹងថ្លៃដើមប្រតិបត្តិការផ្ទាល់បន្ថែម និងត្រូវបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃដករំលស់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត((ត)

### ៣.១០ វិនិយោគលើមូលបត្រ

វិនិយោគលើមូលបត្រ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺជាការវិនិយោគក្នុងឧបករណ៍ហិរញ្ញវត្ថុជាមូលធន ដែលត្រូវបានវាស់វែងតាម FVOCI និងការវិនិយោគមូលបត្រកម្មសិទ្ធិដែលវាស់វែងតាមតម្លៃដករំលស់។

### ៣.១១ ទ្រព្យ និងបរិក្ខារ

**ការទទួលស្គាល់ និងការវាស់វែង**

ទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់ពីឱនភាពតម្លៃបង្គរ ប្រសិនបើមាន។

នៅពេលដែលធាតុរបស់ទ្រព្យ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នារបស់ទ្រព្យ និងបរិក្ខារ។

**ចំណាយជាបន្តបន្ទាប់**

ចំណាយជាបន្តបន្ទាប់ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោង ប្រសិនបើមានភាពប្រាកដថាវាបានផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់សម្ព័ន្ធធនាគារ និងធនាគារ លើសពីស្តង់ដាដើម។ ការជួសជុល និងថែទាំជាប្រចាំ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងឆ្នាំដែលបានកើតឡើង។

**រំលស់**

រំលស់ត្រូវបានគណនាដើម្បីលុបចេញនូវថ្លៃដើមរបស់ទ្រព្យ និងបរិក្ខារ ដកតម្លៃនៅសល់ ដោយប្រើវិធីសាស្ត្ររំលស់ថេរ ផ្អែកលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារ និងត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងចំណេញ ឬខាត។

អាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារ មានដូចខាងក្រោម៖

| | **អាយុកាលប្រើប្រាស់** |
|---|---|
| ការកែលម្អអគារជួល | ៣ - ១០ ឆ្នាំ |
| យានយន្ត | ៣ - ៥ ឆ្នាំ |
| កុំព្យូទ័រ | ៣ - ៥ ឆ្នាំ |
| បរិក្ខារ | ៣ - ៥ ឆ្នាំ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | ៣ - ៥ ឆ្នាំ |

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### ៣.១១ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

រំលស់ (ត)

ដីធ្លីមានអាយុកាលមិនកំណត់ និងមិនត្រូវបានគិតរំលស់ទេ។

ការងារកំពុងដំណើរការ មិនត្រូវបានគិតរំលស់ទេនៅក្នុងអំឡុងពេលសាងសង់ រហូតដល់ពេលដែលទ្រព្យដែលពាក់ព័ន្ធបានបញ្ចប់ និងដាក់ឱ្យប្រើប្រាស់។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃនៅសល់ ត្រូវពិនិត្យឡើងវិញ និងកែតម្រូវឱ្យបានសមស្រប នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍។

ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបចេញពីបញ្ជី។

### ៣.១២ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានអាជ្ញាប័ណ្ណ និងសូហ្វវែរ និងត្រូវបានបង្ហាញតាមតម្លៃដើម ដករំលស់បង្គរ និងការ ខាតបង់ពីឱនភាពតម្លៃបង្គរប្រសិនបើមាន។

ចំណាយជាបន្តបន្ទាប់លើអាជ្ញាប័ណ្ណ និងសូហ្វវែរ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោង ប្រសិនបើប្រាកដថាវាបានផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតលើសពីស្តង់ដាដើម។ រាល់ការចំណាយជាបន្តបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងឆ្នាំដែលបានកើតឡើង។

អាជ្ញាប័ណ្ណ និងសូហ្វវែរ ត្រូវបានធ្វើរំលស់ទៅក្នុងចំណេញ ឬខាត ដោយផ្អែកលើមូលដ្ឋានថេរ គិតចាប់ពីពេលដែលអាចប្រើប្រាស់បាន។

អាយុកាលប្រើប្រាស់របស់ទ្រព្យអរូបីសម្រាប់ឆ្នាំបច្ចុប្បន្ន និងឆ្នាំប្រៀបធៀបគឺដូចខាងក្រោមៈ

| | |
|---|---|
| សូហ្វវែរ និងអាជ្ញាប័ណ្ណ | ៣ - ៧ ឆ្នាំ |

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃនៅសល់ ត្រូវពិនិត្យឡើងវិញ និងកែតម្រូវឱ្យបានសមស្រប នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍។

ការងារកំពុងដំណើរការ ប្រសិនបើមាន មិនត្រូវបានរំលស់រហូតដល់ទ្រព្យសកម្មអរូបីពាក់ព័ន្ធបានសាងសង់ចប់សព្វគ្រប់ និងប្រើប្រាស់ក្នុងប្រតិបត្តិការ។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### ៣.១៣ ភតិសន្យា

សម្ព័ន្ធធនាគារ និងធនាគារ ត្រូវធ្វើការវាយតម្លៃ ថាតើកិច្ចសន្យាមានភតិសន្យាដែរឬទេ នៅពេលចាប់ផ្តើមកិច្ចសន្យា។

**ភតិសន្យាក្នុងនាមជាភតិក:**

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់សិទ្ធិក្នុងការប្រើទ្រព្យសកម្ម និងបំណុលភតិសន្យា ចំពោះគ្រប់កិច្ចសន្យាភតិសន្យាទាំងអស់ ដែលសម្ព័ន្ធធនាគារ និងធនាគារ គឺជាភតិក: លើកលែងតែភតិសន្យារបស់ទ្រព្យសកម្មដែលមានតម្លៃទាបនិងភតិសន្យារយៈពេលខ្លី។ សម្រាប់ភតិសន្យា របស់ទ្រព្យសកម្មដែលមានតម្លៃទាប ធនាគារទទួលស្គាល់ការទូទាត់ភតិសន្យាជាចំណាយប្រតិបត្តិការ តាមមូលដ្ឋានថេរ ដោយផ្អែកទៅតាមរយៈពេលភតិសន្យា។

*<u>បំណុលភតិសន្យា</u>*

បំណុលភតិសន្យា ត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ន នៃការទូទាត់ភតិសន្យា ដែលមិនទាន់បានបង់នៅពេលចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារ ដោយប្រើអត្រាកម្ចីបន្ថែម ដែលជាអត្រាការប្រាក់សម្ព័ន្ធធនាគារ និងធនាគារ នឹងត្រូវបង់ដើម្បីខ្ចីប្រាក់ក្នុងការទទួលបានទ្រព្យសកម្មមួយ ដែលមានតម្លៃសិទ្ធិក្នុងការប្រើទ្រព្យសកម្មនៅក្នុងស្ថានភាពសេដ្ឋកិច្ចស្រដៀងគ្នា ដោយផ្អែកលើលក្ខខណ្ឌស្រដៀងគ្នា និងទ្រព្យដាក់ធានាស្រដៀងគ្នា។

សម្ព័ន្ធធនាគារ និងធនាគារកំណត់អត្រាកម្ចីបន្ថែម ដោយប្រើប្រាស់អត្រាការប្រាក់ពីប្រភពហិរញ្ញប្បទានខាងក្រៅ និងធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងរយៈពេលភតិសន្យា និងប្រភេទទ្រព្យសកម្មនៃភតិសន្យា។

ការទូទាត់ភតិសន្យាដែលត្រូវបញ្ចូលទៅក្នុងការវាស់វែងបំណុលភតិសន្យា រួមមានៈ

- ការទូទាត់ភតិសន្យាថេរ ដកចេញនូវការតបស្នងភតិសន្យាប្រសិនបើមាន
- ការទូទាត់ភតិសន្យាអថេរដែលអាស្រ័យលើសន្ទស្សន៍ ឬអត្រាមួយ ដែលវាស់វែងលើកដំបូងដោយប្រើសន្ទស្សន៍ ឬអត្រានៅកាលបរិច្ឆេទចាប់ផ្តើម
- ការបង់ប្រាក់ពិន័យលើការបញ្ចប់ភតិសន្យា ប្រសិនបើលក្ខខណ្ឌភតិសន្យា បានឆ្លុះបញ្ចាំងពីការអនុវត្តជម្រើសក្នុងការបញ្ចប់ភតិសន្យា។

បំណុលភតិសន្យា ត្រូវបានបង្ហាញជាធាតុដាច់ដោយឡែកមួយ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

បំណុលភតិសន្យា ត្រូវបានវាស់វែងជាបន្តបន្ទាប់ ដោយការកើនឡើងនូវតម្លៃយោង ដើម្បីឆ្លុះបញ្ចាំងពីការប្រាក់លើបំណុលភតិសន្យា (ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព) និងដោយការថយចុះនូវតម្លៃយោង ដើម្បីឆ្លុះបញ្ចាំងពីការបង់សងភតិសន្យា។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### ៣.១៣ ភតិសន្យា (ត)

ភតិសន្យាក្នុងនាមជាភតិកៈ (ត)

*បំណុលភតិសន្យា (ត)*

សម្ព័ន្ធធនាគារ និងធនាគារ ធ្វើការវាស់វែងបំណុលភតិសន្យាឡើងវិញ (និងធ្វើនិយ័តកម្មជាមួយនឹងសិទ្ធិប្រើប្រាស់ទ្រព្យសកម្មដែលពាក់ព័ន្ធ) នៅពេលដែលៈ

- លក្ខខណ្ឌភតិសន្យាមានការផ្លាស់ប្តូរ ដែលក្នុងករណីនេះ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញ ដោយការធ្វើអប្បហារការទូទាត់ភតិសន្យាដែលបានកែប្រែ តាមអត្រាអប្បហារដែលបានកែប្រែ។
- កិច្ចសន្យាភតិសន្យាត្រូវបានកែប្រែ ហើយភតិសន្យាដែលបានកែប្រែនេះ មិនត្រូវបានគិតថាជាភតិសន្យាដាច់ដោយឡែកមួយទៀតនោះទេ ដែលក្នុងករណីនេះ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញ ដោយការធ្វើអប្បហារការទូទាត់ភតិសន្យាដែលបានកែប្រែ តាមអត្រាអប្បហារដែលបានកែប្រែ។

*សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម*

សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម រួមមាន ការវាស់វែងដំបូងរបស់បំណុលភតិសន្យាដែលពាក់ព័ន្ធ ការទូទាត់ភតិសន្យាដែលបានធ្វើឡើងនៅពេល ឬមុនពេលថ្ងៃចាប់ផ្តើម និងថ្លៃដើមដំបូងពាក់ព័ន្ធផ្ទាល់ប្រសិនបើមាន។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានវាស់វែងជាបន្តបន្ទាប់ តាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ពីឱនភាពតម្លៃបង្គរ។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវធ្វើរំលស់ដោយផ្អែកលើថេរវេលារបស់ភតិសន្យា ឬអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មដែលពាក់ព័ន្ធ មួយណាលឿនជាង។ រំលស់ត្រូវចាប់ផ្តើមនាកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ បន្ថែមពីនេះ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មគឺកាត់បន្ថយជារៀងរាល់ពេល តាមរយៈ ឱនភាពតម្លៃ។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានបង្ហាញជាធាតុដាច់ដោយឡែកមួយនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ៣.១៤ ឱនភាពតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពតម្លៃ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានវិញរបស់ទ្រព្យសកម្ម ត្រូវបានធ្វើឡើង។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### ៣.១៤ ឱនភាពតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)

សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មដទៃទៀត (ហៅកាត់ថា "ឯកតាបង្កើតសាច់ប្រាក់")។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ។

ការខាតបង់លើឱនភាពតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬឯកតាបង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ។

ការខាតបង់លើឱនភាពតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

ការខាតបង់លើឱនភាពតម្លៃ ត្រូវកត់ត្រាបញ្ច្រាសមកវិញ ត្រឹមកម្រិតមួយដែលមិនធ្វើឱ្យតម្លៃយោងរបស់ទ្រព្យសកម្មនេះ លើសពីតម្លៃយោងដករំលស់ដែលត្រូវកំណត់ ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់លើឱនភាពតម្លៃ។

### ៣.១៥ ប្រាក់បញ្ញើ មូលបត្របំណុល ប្រាក់កម្ចី និងអនុបំណុល

ប្រាក់បញ្ញើរបស់អតិថិជន និងគ្រឹះស្ថានហិរញ្ញវត្ថុ មូលបត្របំណុល ប្រាក់កម្ចី និងអនុបំណុល ជាប្រភពហិរញ្ញប្បទានរបស់សម្ព័ន្ធធនាគារ និង ធនាគារ។

ប្រាក់បញ្ញើរបស់អតិថិជននិងគ្រឹះស្ថានហិរញ្ញវត្ថុ មូលបត្របំណុល ប្រាក់កម្ចី និងអនុបំណុល ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការផ្ទាល់បន្ថែម និងត្រូវបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃដករំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

អនុបំណុល គឺជាបំណុលរយៈពេលវែង ដែលការបង់សងប្រាក់ដើម ត្រូវធ្វើឡើងបន្ទាប់ពីការបង់សងបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធធនាគារ និងធនាគារ។ អនុបំណុលដែលបានអនុម័តដោយធនាគារជាតិនៃកម្ពុជា ត្រូវបានចាត់ទៅក្នុងគណនីថ្នាក់ទី២ ក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធ របស់ សម្ព័ន្ធធនាគារ និងធនាគារ ស្របតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត (ត)

### ៣.១៦ សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលសម្ព័ន្ធធនាគារ និងធនាគារ មានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្តសំវិធានធនត្រូវបានកំណត់ ដោយការធ្វើអប្បហារលំហូរទឹកប្រាក់ដែលរំពឹងថានឹងត្រូវបង់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។

### ៣.១៧ បំណុលយថាភាព

បំណុលយថាភាពនឹងមិនត្រូវបានទទួលស្គាល់លើកដំបូង ប៉ុន្តែអាចត្រូវបានលាតត្រដាងសម្រាប់ព័ត៌មានសំខាន់ៗ លើកលែងតែភាពអាចកើតឡើងនូវលំហូរចេញអត្ថប្រយោជន៍សេដ្ឋកិច្ចនៅពេលអនាគត។ បំណុលយថាភាពអាចផ្លាស់ប្តូរពីការរំពឹងទុកលើកដំបូង។ ដូច្នេះពួកវាត្រូវបានវាយតម្លៃបន្តបន្ទាប់ដើម្បីកំណត់លំហូរចេញអត្ថប្រយោជន៍សេដ្ឋកិច្ចដែលអាចកើតឡើង។ ប្រសិនបើលំហូរអត្ថប្រយោជន៍សេដ្ឋកិច្ចនៅពេលអនាគតអាចកើតឡើង សំវិធានធនគឺត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

### ៣.១៨ ទ្រព្យសកម្មយថាភាព

ទ្រព្យសកម្មយថាភាពនឹងមិនត្រូវបានទទួលស្គាល់លើកដំបូង ប៉ុន្តែអាចត្រូវបានបង្ហាញសម្រាប់ព័ត៌មានសំខាន់ៗជាញឹកញាប់នៅពេលព្រឹត្តិការណ៍មិនអាចរំពឹងទុកដទៃទៀត ឬមិនបានគ្រោងទុកកើតឡើងបណ្តាលមកពីភាពដែលអាចទៅរួច នៃលំហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ចទៅលើសម្ព័ន្ធធនាគារ និងធនាគារ។ ទ្រព្យសកម្មយថាភាពត្រូវបានវាយតម្លៃបន្តបន្ទាប់ដើម្បីធានាថាទ្រព្យសកម្មយថាភាព គឺត្រូវបានឆ្លុះបញ្ចាំងសមស្របនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ប្រសិនបើវាច្បាស់ថាលំហូរចូលនូវ អត្ថប្រយោជន៍សេដ្ឋកិច្ចនឹងកើតឡើង ទ្រព្យសកម្ម និងចំណូលទាក់ទិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

### ៣.១៩ ទុនបម្រុង

#### ទុនបម្រុងស្របច្បាប់

មុនពេលត្រូវបានទិញដោយធនាគារ Bank of Ayudhya PCL ("Krungsri") ដែលជាម្ចាស់ភាគហ៊ុនថ្មី លក្ខន្តិកៈធនាគារតម្រូវឱ្យបង្វែរចេញពីប្រាក់ចំណេញរក្សាទុកនូវចំនួនដែលស្មើនឹង ៥% នៃប្រាក់ចំណេញសុទ្ធសម្រាប់ ការិយបរិច្ឆេទមុនចូលក្នុងទុនបម្រុង។ ការបង្វែរនេះនឹងបញ្ឈប់នៅពេលដែលទុនបម្រុងមានចំនួនស្មើនឹង ១០% នៃដើមទុនបានចុះបញ្ជីរបស់ធនាគារ។ យោងតាមលក្ខន្តិកៈថ្មីដែលអនុម័តដោយក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ ពុំមានការបង្វែរចូលទុនបម្រុងទៀតនោះទេ បន្ទាប់ពីធនាគារត្រូវបានកាន់កាប់ទាំងស្រុងដោយ Krungsri។

## ៣. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត(ត)

### ៣.១៩ ទុនបម្រុង (ត)

**សំវិធានធនតាមបទប្បញ្ញត្តិ និងទុនបម្រុងតាមបទប្បញ្ញត្តិ**

នៅថ្ងៃ១ ខែធ្នូ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសលេខ B៧-០១៧-៣៤៤ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ដើម្បីធានាបានភាពត្រឹមត្រូវនៃការទទួលស្គាល់ការវាស់វែងការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន របស់គ្រឹះស្ថាន។

ហ្វាស៊ីលីធី សំដៅដល់ឥណទាន និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ទាំងនៅក្នុង ឬក្រៅតារាងតុល្យការដែលគ្រឹះស្ថានបានផ្តល់ទៅឱ្យសមភាគី ហើយហ្វាស៊ីលីធីនេះអាចបង្កហានិភ័យឥណទានដល់គ្រឹះស្ថាន។

យោងតាមប្រកាសនេះសម្ព័ន្ធធនាគារ និងធនាគារត្រូវធ្វើសំវិធានធនសម្រាប់ហ្វាស៊ីលីធី ដែលមានឱនភាពតម្លៃ ដោយអនុលោមតាមបទប្បញ្ញត្តិ ទន្ទឹមគ្នានឹងការគណនាសំវិធានធនដោយយោងតាមស្តង់ដា CIFRSs។ ចំនួនលើសនៃសំវិធានធនដែលបានមកពីការគណនាស្របតាមបទប្បញ្ញត្តិ ប្រៀបធៀបទៅនឹងការគណនាតាម CIFRSs នឹងត្រូវផ្ទេរពីគណនីប្រាក់ចំណេញរក្សាទុកទៅក្នុងគណនីទុនបម្រុងតាមបទប្បញ្ញត្តិ ក្នុងខ្ទង់មូលធន។

*ការកត់ត្រឡប់វិញនៃទុនបម្រុងតាមបទប្បញ្ញត្តិ*

នៅពេលដែលឱនភាពនៃការខាតបង់ត្រូវបានគណនា តាមបទប្បញ្ញត្តិសំវិធានធនតិចជាងការគណនាតាមCIFRSs ទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានប្តូរទៅចំនួនទឹកប្រាក់ដែលមិនលើសពីចំនួនដែលនឹងត្រូវកំណត់ ហើយមិនមានទុនបម្រុងបទប្បញ្ញត្តិត្រូវបានទទួលស្គាល់ក្នុងឆ្នាំមុន។

នៅថ្ងៃ១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំលេខ ធ៧-០១៨-០០១ ដើម្បីបញ្ជាក់បន្ថែមលើការអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន។ យោងតាមរយៈសារាចរនេះ សម្ព័ន្ធធនាគារ និងធនាគារ ត្រូវធ្វើការគណនាសំវិធានធនសម្រាប់ហ្វាស៊ីលីធីដែលមានឱនភាពតម្លៃ ដោយអនុលោមតាមបទប្បញ្ញត្តិ ដោយហ្វាស៊ីលីធីត្រូវបានចាត់ជា ៥ថ្នាក់ ដែលមានអត្រាសំវិធានធន ដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| *សំវិធានធនទូទៅ* | | |
